ព្រះគ្រូបញ្ញាលិខិត ខោល ប្រាក់
ឥន្ទបញ្ញា វត្តលង្កា

# ឧបោសថវិនិច្ឆ័យ

សួរ ឆ្លើយ

អំពីឧបោសថសីល

ឧទ្ទិសចំពោះកម្លោះក្នុងសកលកម្ពុជរដ្ឋ

ក្រសួងការត្រួតត្រាលិខិត
បានអនុញ្ញាតហើយ

ចម្លងដោយ

លេខ១៣៦អឺសុន្យ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស២៥៤១ គ.ស១៩៩៨

ព្រះគ្រូបញ្ញាលិខិត ខោល-ប្រាក់
ឥន្ទបញ្ញោ វត្តលង្កា

# ឧបោសថវិនិច្ឆ័យ

សួរ ឆ្លើយ
អំពីឧបោសថសីល
ឧទ្ទិសបំពោះកម្ពោជក្នុងសកលកម្ពុជរដ្ឋ
ក្រសួងការត្រួតត្រាលិខិត
បានអនុញ្ញាតហើយ

ព.ស ២៤៩៦ គ.ស ១៩៥៣

# អារម្ភកថា

មូលហេតុដែលនាំអោយកើតជាសៀវភៅឧបោសថវិនិច្ឆ័យនេះឡើង គឺដោយសារលោកគិលានុបដ្ឋាក **ម៉ុម~ឈុំ** នឹងនាង **ឈុំ~ម៉ូសែន** ជាបុត្រីមានសាទរសទ្ធាជ្រះថ្លា កើតធម្មសង្វេគចំពោះវិញ្ញាណក្ខន្ធរបស់ឧបាសិកា **ជា~ស្រស់** ជាភរិយាគឺត្រូវជាមាតានាង **ឈុំ~ម៉ៃសែន** ដើម្បីធ្វើទក្ខិណានុប្បទានឧទ្ទិសចំណែកផលចំពោះវិញ្ញាណក្ខន្ធរបស់ឧបោសិកានោះ ក៏បានចូលទៅអារាធនាខ្ញុំថា សូមឱ្យតែងធម៌ណាមួយ ដែលមានសារៈសំខាន់ដើម្បីនឹងជួយគាំពារសេចក្តីប្រតិបត្តិរបស់ពួកគ្រហស្ថ ឱ្យរឹងរឹតតែមាំមួនក្នុងព្រះពុទ្ធសាសនាតទៅ។

ទើបខ្ញុំខំប្រឹងឆ្លៀតរកឱកាស ដើម្បីនឹងរៀបរៀងធម៌នេះឡើង ព្រោះយល់ឃើញថា ធម៌នេះមិនទាន់បោះពុម្ពផ្សាយនៅឡើយ ហើយក៏ជាការមានប្រយោជន៍សំខាន់បំផុតដល់ពួកគ្រហស្ថដែលបានរក្សានូវឧបោសថសីល នឹងជាគ្រឿងបំភ្លឺ សតិបញ្ញា និងជាកិច្ចសម្រាប់ពន្យល់នូវកិច្ចនៃឧបោសថ ដែលខ្លួនបានរក្សាហើយ កុំឱ្យសង្ស័យឡើយ ។

ខ្ញុំបានដកស្រង់យកអំពីគម្ពីរទាំងឡាយមានគម្ពីរមង្គលត្ថទីបនី

អដ្ឋកថាមង្គលសូត្រជាដើមមករួបរួម នឹងរៀបរៀងចងក្រងជាប្រស្នាបុច្ឆាវិសជ្ជនា ដើម្បីនឹងឱ្យងាយយល់ដល់សិក្ខាកាមកុលបុត្តទាំងឡាយ ដែលទើបបានសិក្សាថ្មីៗ ឱ្យបានយល់ដោយងាយ ។

លុះរៀបរៀងចប់ហើយ ខ្ញុំក៏បានយកទៅប្រគេនសម្តេចព្រះធម្មលិខិតឧត្តមសិក្សាគណមហានិកាយទត សម្តេចក៏មានព្រះទ័យសោ-មនុស្សប្រកបដោយមេត្តាជួយពិនិត្យផ្ទៀងផ្ទាត់ឱ្យ ថាគួរនឹងបោះពុម្ពបាន

ទាំងលោកអាចារ្យ ៥ រូបទៀតគឺ

ព្រះគ្រូបូរស្មិមាសី អ៊ូ ចេវ ១

លោកគ្រូអាចារ្យ ឈឹម-ទូច ១

លោកមហា នង-សមិទ្ធ ១

លោក ឯន-ប៉ង់ ១

ក៏បានជួយពិនិត្យដែរ រួចហើយខ្ញុំបានឱ្យលោកសាមណេរកឹម-យ៉នដែលជាសិស្សរបស់ខ្ញុំ សរសេរចម្លងត្រឹមត្រូវស្រេចហើយ ទើបបានចាត់ការបោះពុម្ពផ្សាយ ដើម្បីជាសាធារណៈទូទៅដល់កុលបុត្តទាំងឡាយ ដែលត្រូវការក្នុងសកលកម្ពុជរដ្ឋ ។

សូមអភ័យទោសអំពីបណ្ឌិតជាតិទាំងឡាយ ក្រែងខ្ញុំរៀបរៀងទៅហើយភ្លាំងភ្លាត់ត្រង់បទណាមួយ សូមជួយកែតម្រង់ឱ្យទានផង ។

ដោយអំណាចវិរិយភាពដែលខ្ញុំរៀបរៀងធម៌នេះ សូមឧទ្ទិសចំណែកផល ជូនចំពោះបុព្វការីជនទាំងឡាយមានមាតាបិតា គ្រូឧបជ្ឈាយាចារ្យជាដើម សូមឱ្យទទួលយកនូវផលដែលខ្ញុំបានឧទ្ទិសជូនប្រគេនទៅនេះ ហើយសូមឱ្យបានសម្រេចឥដ្ឋមនុញ្ញផលគ្រប់ៗ គ្នាកុំគប្បីឃ្លៀងឃ្លាតឡើយ ។

សូមឱ្យព្រះពុទ្ធសាសនារបស់ព្រះសាក្យមុនីប្រតិស្ឋានទៅឱ្យបានអស់កាលជាយូរអង្វែងទៅ ។

សូមសិរីជោគជ័យថ្វាយដល់ព្រះប្រិយម ។

សូមសេចក្តីសុខក្សេម កើតមានដល់ប្រជានិករទូទៅក្នុងពិភពលោក

ព្រះគ្រូបញ្ញាលិខិត ខោល-ប្រាក់ ឥន្ទបញ្ញោ

វត្តលង្កា ក្រុងភ្នំពេញ

# ឧបោសថវិនិច្ឆ័យ

## នមត្ថុរតនត្តយស្ស

សូមនមស្សការ ចំពោះព្រះរតនត្រ័យទាំងបី ដោយសេចក្តីគោរព។

បុច្ឆា ឧបោសថ ប្រែដូចម្តេច ?

វិសជ្ជនា ឧបោសថ ប្រែថា ចូលទៅជិតរក្សា ឬថា ដុតកម្ទេចនូវ ឧបក្កិលេសធម៌ ដូចបទវិគ្គហៈថា: **(ឯករត្តិន្ទិវំ អដ្ឋង្គុបេតំ ឧបោសថំ) ឧបវសតីតិ** > **ឧបោសថោ (សភាវោ)** (សភាវៈ) ណា ចូលទៅជិតរក្សា (នូវឧបោសថប្រកបដោយអង្គ៨អស់ ថ្ងៃ១យប់១ (សភាវៈ) នោះហៅថាឧបោសថ ;**ឧបក្កិលេសេ ឧសតិ** ;**ឌហតិៈ ឧបតាបេតិវាតិ** > **ឧបោសថោ** ន័យមួយវិញទៀតថា (សភាវៈ) ណាដុតកម្ទេច ឬថាញុំាងឧបក្កិលេសទាំងឡាយអោយក្តៅ(សភាវៈ) នោះ ឈ្មោះថាឧបោសថ ។

បុ. ឧបោសថបានសេចក្តីថាដូចម្តេច ?

វិ.បានសេចក្តីថា: កិរិយាសមាទានដោយប្រព្រៃនូវអង្គនៃឧបោ-

សថ ទាំង៨ប្រការ ក្នុងកាលដ៏គួរតាមពុទ្ធប្បញ្ញត្តិ ដើម្បីកំចាត់បង់នូវឧបក្កិលេសធម៌ ដែលជាសភាវៈតែងគ្របសង្កត់ នូវសន្តានចិត្តសព្វសត្វឱ្យសៅហ្មង ឈ្មោះថាឧបោសថ ។

បុ. ដែលនឹងកើតឡើងជាឧបោសថនោះតើប្រកបដោយអង្គប៉ុន្មាន ?

វិ. ដែលនឹងកើតឡើងជាឧបោសថនោះប្រកបដោយអង្គបី។

បុ. អង្គបីនោះ គឺអ្វីខ្លះ ? ចូលរាប់

វិ. អង្គបីនោះគឺ :

១. ប្រកបដោយថ្ងៃដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តមានថ្ងៃបកតិ-ឧបោសថជាដើម ។

២. ត្រូវបញ្ចេញវចីភេទឱ្យឮ មិនត្រូវស្ងួតខ្សឹបៗ ។

៣. ត្រូវតាំងចេតនាវៀរគ្រប់សិក្ខាបទនោះៗ ។

បុ. ចុះដែលមិនកើតឡើងជាឧបោសថនោះប្រកបដោយហេតុដូចម្ដេចខ្លះ ?

វិ. ដែលមិនកើតឡើងជាឧបោសថនោះប្រកបដោយសីលភេទ។

បុ. សីលភេទនោះដូចម្តេច ? ចូរអធិប្បាយ

វិ. អធិប្បាយថា: បណ្តាសិក្ខាបទទាំង៨មានចាណាតិបាតជាដើមរឿធ្វើឱ្យកន្លងនូវសិក្ខាបទណាមួយក្នុងថ្ងៃឧបោសថនោះ ហើយទៅសមាទានមិនឡើយជាឧបោសថទេ តែចំណែកវិកាល១ ចាប់តាំងពីថ្ងៃជ្រេពីត្រង់ទៅបរិភោគបាយហើយទៅសមាទាន មិនឡើងជាឧបោ-សថឡើយដូច្នេះឈ្មោះថា សីលភេទ ។

បុ. ឧបោសថដែលនឹងដាច់ទៅនោះ តើប្រកបដោយហេតុប៉ុន្មាន?

វិ. ឧបោសថដែលនឹងដាច់ទៅនោះ ដោយហេតុពីរយ៉ាងគឺ:

**១ សាវជ្ជភេទ** ដាច់ហើយប្រកបដោយទោស គឺប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទណាមួយ ដែលជាលោកវជ្ជសិក្ខាបទ ។

**២ អនវជ្ជភេទ** ដាច់ហើយមិនមានទោសគឺស្លាប់ ។

បុ. សៅហ្មងឧបោសថនោះដូចម្តេច ?

វិ. សៅហ្មងឧបោសថនោះ, អ្នកសមាទានឧបោសថហើយមិនប្រកបកិច្ចដែលត្រូវចំរើន ក្នុងថ្ងៃឧបោសថនោះ ។

បុ. កិច្ចដែលត្រូវចំរើន ក្នុងថ្ងៃឧបោសថនោះ ដូចម្ដេចខ្លះ? ចូលរាប់មកមើល

វិ. កិច្ចដែលត្រូវចំរើន ក្នុងថ្ងៃឧបោសថនោះគឺ :

**១-ការលេន ធម្មសាកច្ឆា** អ្នកសមាទានហើយ ត្រូវសាកសួរប្រឹក្សាអំពីធម្មវិន័យក្នុងកាលដ៏គួរ ។

**២-ការលេន ធម្មស្សវនំ** អ្នកសមាទាន ត្រូវស្ដាប់ធម៌តាមកាលដ៏គួរ ។

**៣-ការលេនសមថៈ** អ្នកសមាទានត្រូវចំរើនសមថកម្មដ្ឋានទាំង ៤០ ណាមួយតាមកាលដ៏គួរដូច្នេះឈ្មោះថាកិច្ចត្រូវចំរើនក្នុងថ្ងៃឧបោសថ ។

បុ. បើមិនប្រកបដោយកិច្ចទាំង៣យ៉ាងនេះទេ, តើឧបោសថនោះដូចម្ដេចទៅ ?

វិ. បើមិនប្រកបដោយកិច្ចទាំង៣យ៉ាងនេះទេ,ឧបោសថនោះមិនរុងរឿង គឺមានអានិសង្សតិច ។

បុ. កម្មដ្ឋានទាំង ៤០ នោះកម្មដ្ឋានប៉ុន្មានដែលចំរើនទៅហើយ

ទុកណាជាកើតសមាធិក្តី មិនកើតសមាធិក្តី ហើយបានអានិសង្សច្រើនជាងគេ ?

វិ. កម្មដ្ឋានទាំង ៤០នោះ ត្រូវយកកម្មដ្ឋាន៣គឺ: អសុភកម្មដ្ឋាន១ , មរណានុស្សតិកម្មដ្ឋាន១, កាយគតាសតិកម្មដ្ឋាន១, ប៉ុន្តែលះបង់មូលកម្មដ្ឋា មិនបាន ត្រូវចំរើនមូលកម្មដ្ឋានមុនសិនទើបចំរើនកម្មដ្ឋានទាំង៣ណាមួយតាមកាលដ៏គួរ ។

បុ. ចុះអ្នកសមាទានឧបោសថរួចហើយ ដល់ពេលល្ងាចទៅសមាទានសីល៥ជាមួយនឹងគេទៀត តើគួរ ឬ ពុំគួរ ?

វិ. ពុំគួរទេ, បើគ្រាន់តែទទួលសរណគមន៍បាន ។

បុ. ហេតុដូចម្តេចបានជាថាពុំគួរ ត្រង់សរណគមន៍ម្តេចក៏ថាគួរ? ចូលអធិប្បាយមកមើល

វិ. បានជាថាពុំគួរនោះ ព្រោះការសមាទានឧបោសថសីលជាសីលខ្ពង់ខ្ពស់ជាង ទាំងចេតនាក៏ខ្ពស់ជាងដែរ ដល់ទៅសមាទានសីល៥នាំឱ្យថយចេតនាទាបមកវិញបានជាថាពុំគួរ ឯក្រៃសរណគមន៍ទើបគួរព្រោះជាកិច្ចត្រូវចំរើន ។

បុ. អ្នកសមាទានឧបោសថ មិនទាន់ពេលពីព្រលឹមទេដល់ពេលថ្ងៃទើបបានទៅទទួលសមាទាន តើពេញជាឧបោសថដែរឬទេ ?

វិ. អ្នកសមាទានចាប់តាំងពីថ្ងៃត្រង់ បើបានអធិដ្ឋានពីព្រលឹមរួចហើយ ទើបពេញបរិបូណ៌ , បើមិនបានអធិដ្ឋានទេបានត្រឹមតែពាក់កណ្តាលហៅថា ឧបឌ្ឍុបោសថ (ឧបោសថពាក់កណ្តាល) ។

បុ. ឧបោសថកម្មនោះតើដូចម្តេច ?

វិ. អំពើដែលត្រូវធ្វើក្នុងថ្ងៃឧបោសថគឺ ធ្វើនូវកិច្ចឧបោសថដែលត្រូវចំរើន ។

បុ. ចុះឧបោសថកាលនោះ តើដូចម្តេច ?

វិ. ឧបោសថកាលគឺថ្ងៃដែលត្រូវរក្សានូវឧបោសថ ដែលព្រះពុទ្ធ ជាម្ចាស់ទ្រង់បញ្ញត្តមកទាំងប៉ុន្មាន មានថ្ងៃអដ្ឋមីជាដើម ។

បុ. ចុះឧបោសថសីលនោះតើដូចម្តេចទៅ ?

វិ. ឧបោសថសីលនោះគឺសីលសម្រាប់ដុតបំផ្លាញនូវឧបក្កិលេសឬថាជាសីលសម្រាប់បង្ក្រាប់ ឬបង្ក្រេម ឬថាបន្ថយនូវកំឡាំងតណ្ហាអស់រយៈថ្ងៃ១យប់១បុណ្ណោះ កុំអោយកើតឡើងបានប្រកបដោយអង្គ

ព្រាំបីមានចាណាតិចាតជាដើមមានឧច្ចាសយនៈជាទីបំផុត ។

បុ. ឧបោសថសីលនេះព្រះអង្គទ្រង់ប្រារព្ធចំពោះបុគ្គលណាមុនគេ ?

វិ. ព្រះអង្គទ្រង់ប្រារព្ធចំពោះមហានាមជាសក្យបុត្រមុនឧបាសកទាំងពួង ។

បុ. ចុះឧបោសថនោះមានតែក្នុងពុទ្ធកាលទេ ឬ ១ ក៏ក្រៅពុទ្ធកាលមានដែរ ?

វិ. ខាងក្នុងពុទ្ធកាលក៏មាន ខាងក្រៅពុទ្ធកាលក៏មាន ។

បុ. ចុះបោសថខាងក្រៅពុទ្ធកាលនោះតើដូចម្តេចខ្លះ ? ចូរអធិប្បាយ

វិ. ឯឧបោសថខាងក្រៅពុទ្ធកាលនោះ គឺអ្នកប្រាជ្ញទាំងឡាយលោកពោលថា គ្រាន់តែអត់មិនបរិភោគអាហារក្នុងវេលាវិកាលអស់កំណត់ថ្ងៃ១យប់១ ឱ្យឈ្មោះថាឧបោសថក្នុងកាលនោះប៉ុណ្ណោះ ។

បុ. ចុះលោកកំណត់ថ្ងៃឧបោសថក្នុងមួយខែ១ មានប៉ុន្មានថ្ងៃ ? គឺថ្ងៃណាខ្លះ ?

វិ. លោកកំណត់ក្នុងមួយខែមាន៦ថ្ងៃ គឺ អាហារសីថ្ងៃ១៥ កើត ១៥ រោច១,អដ្ឋមី ថ្ងៃ៨កើត រោច១, ឯកាទសីថ្ងៃ១១ កើត១១ រោច១, រួមត្រូវជា៦ថ្ងៃក្នុងមួយខែៗ ។

បុ. ឧបោសថនោះតើមានប៉ុន្មានសិក្ខាបទ ? អ្វីខ្លះ .

វិ. មាន៦សិក្ខាបទគឺ: បាណា-អទិន្នា-អព្រហ្ម មុសា សុរា នឹងវិកាល, សិក្ខាបទទាំង៦នេះលោកសន្មតហៅថា ឧបោសថសីល ក្នុងសម័យនោះ ។ ព្រោះថា: ឧបោសថនេះ មិនមែនជាអដ្ឋង្គិកឧ-បោសថ ដែលប្រកបដោយអង្គទាំង៨នេះឡើយ ឯអដ្ឋង្គិកឧបោសថ នេះមានតែក្នុងពុទ្ធកាល ខាងក្រៅពុទ្ធកាលពុំមានឡើយ ។

បុ. ឧបោសថក្នុងពុទ្ធកាលនោះ តើពួកសប្បុរសទាំងឡាយ គប្បីរក្សាដូចម្ដេច ?

វិ. ឧបោសថក្នុងពុទ្ធកាលនោះ គឺពួកសប្បុរស់ទាំងឡាយគប្បី រក្សាឱ្យសមគួរតាមពុទ្ធានុញ្ញាត គឺថាគប្បីរក្សាក្នុងថ្ងៃដែលព្រះអង្គទ្រង់ អនុញ្ញាតមកហើយ ដែលហៅថាឧបោសថកាលនោះ ។

បុ. ឧបោសថមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ ? ចូលរាប់មកមើល ?

វិ. ឧបោសថមានពីរយ៉ាងគឺ: បកតិឧបោសថ១, បដិជាគរឧបោ-សថ១ ។

បុ. បកតិឧបោសថប្រែថាដូចម្តេច ?

វិ. ប្រែថាឧបោសថដែលប្រព្រឹត្តទៅដោយប្រក្រតី គឺឧបោសថដែលអ្នកប្រាជ្ញទាំងទាំងឡាយលោកធ្វើមកហើយអំពីដើម ។

បុ. ក្នុង១ខែចែកជាបក្ខមានប៉ុន្មាន ?

វិ. មានពីរបក្ខគឺ: សុក្កបក្ខ១, កាឡបក្ខ១ ។

បុ. ចុះកាលនៃបកតិឧបោសថនេះក្នុង១ខែមានប៉ុន្មានថ្ងៃៗ ណាខ្លះ ?

វិ. ឯថ្ងៃដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតទុកមកក្នុង១ខែៗមាន៨ថ្ងៃគឺ:សុក្កបក្ខចំណែកខាងខ្នើត៤ ថ្ងៃគឺ:ថ្ងៃ៥ កើត៨កើត១៤ កើត១៥ ; កាឡបក្ខ ចំណែកខាងរនោចមាន៤ ថ្ងៃគឺ:ថ្ងៃ៥រោច ៨រោច ១៤រោច ១៥រោច រួមត្រូវជា៨ថ្ងៃក្នុង១ខែ ឈ្មោះថាបកតិឧបោសថកាល ។

បុ. ចុះបដិជាគរឧបោសថនោះប្រែថា ដូចម្តេច ?

វិ. ប្រែឧបោសថកម្មនៃបុគ្គលអ្នកភ្ញាក់រលឹករឿយៗ ។

បុ. ចុះពាក្យថា:ភ្ញាក់រលឹករឿយៗនោះតើដូចម្តេច?ចូរអធិប្បាយ

វិ. ពាក្យថាភ្ញាក់រលឹករឿយៗ នោះគឺការខ្វល់ខ្វាយខំប្រឹងប្រែងធ្វើបុណ្យឱ្យទាន់មានប្រការផ្សេងៗ គឺនឹករលឹកដល់ឧបោសថសីលជាកុសលដែលខ្លួនត្រូវសន្សំឈ្មោះថា ជាអ្នកភ្ញាក់រលឹករឿយៗ ។

បុ. បដិជាគរឧបោសថនោះ ឧបាសក-សិកាទាំងឡាយតាំងចិត្តរក្សាដូចម្តេចខ្លះ ?

វិ. ឯបដិជាគរឧបោសថនោះ ឧបាសក-សិកាទាំងឡាយគប្បីដុសខាត់ជំរះសមអាតចិត្ត នឹករលឹកដល់សិក្ខាបទទាំង៨ ដែលជាអង្គនៃឧបោសថសីល តែមិនត្រូវសមាទានឡើយ គឺគ្រាន់តែធ្វើចិត្តឱ្យឃោលឬថាឱ្យថយកម្លាំង ដើម្បីនឹងដោះចិត្តឱ្យចេញចាកកាមគុណទាំង ៥ ប្រការមានរូបជាដើម ហើយបំរុងជូនដំណើរនៃបកតិឧបោសថ គឺគ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង ៨ មានបាណាតិបាតជាដើមប៉ុណ្ណោះ ។

បុ. ចុះថ្ងៃជាបដិជាគរឧបោសថកាលនោះ តើក្នុង ១ ខែមានប៉ុន្មានថ្ងៃ ? គឺថ្ងៃណាខ្លះ ?

វិ. ក្នុង ១ ខែមាន ១១ ថ្ងៃគឺត្រង់ថ្ងៃ ៤ កើត, ៦ កើត, ៧ កើត, ៩ កើត, ១៣ កើត, ១ រោច, ៤ រោច, ៦ រោច, ៧ រោច, ៩រោច, ១៣រោច, ។ បើខែខ្វះត្រង់១៣ រោច ថយមក ១២ រោចវិញ ថ្ងៃទាំង ១១ ក្នុងខែនីមួយៗ នេះជាថ្ងៃខាងដើមនឹងខាងចុងនៃបកតិឧបោសថ ឬថាជាថ្ងៃអមនៃបកតិឧបោសថគឺ: ជាកាលនៃបដិជាគរឧបោសថនោះឯង ។

បុ. ឯថ្ងៃដែលទំនេរ មិនមែនជាថ្ងៃឧបោសថនោះប៉ុន្មានថ្ងៃ ? គឺថ្ងៃណាខ្លះ ?

វិ. ឯថ្ងៃដែលទំនេរក្រៅអំពីបកតិឧបោសថ នឹងបដិជាគរឧបោសថនោះមាន ១១ ថ្ងៃគឺ: ១ កើត, ៣ កើត, ១០ កើត, ១១ កើត, ១២ កើត, ១ រោច, ២រោច, ១០ រោច, ១១ រោច, ១២ រោច ។ បើខែខ្វះមានតែ១០ថ្ងៃ ព្រោះថ្ងៃ ១២ រោចទុកជាថ្ងៃបដិគរឧបោសថ ថ្ងៃទាំង ១១ ឬ ១០ មិនមែនជាកាល នៃឧបោសថណាមួយឡើយគ្រប់ខែទាំងអស់គឺ: ជាថ្ងៃត្រូវរក្សាបញ្ចសីល ។

បុ. ពាក្យដែលបានពោលថាខែទាំងអស់នេះជាកាលគួរសប្បុរស

ទាំងឡាយនាំគ្នារក្សានូវបញ្ចសីលនោះតើលោកពោលដោយអំណាចអ្វី?

វិ. លោកពោលដោយអំណាចនៃបុគ្គលដែលមិនបានរក្សានូវ បាដិហារិយបក្ខឧបោសថ, គឺថ្ងៃឧបោសថដែលមានក្នុងជុណ្ហបក្ខ និង កាឡបក្ខ ។

បុ. ចុះបាដិហារយបក្ខឧបោសថនោះ បានដល់បុគ្គលបែបណា?

វិ. បានដល់បុគ្គលអ្នកប្រកបដោយកិច្ចការងារច្រើន នឹងរក្សា បកតិឧបោសថនឹងបដិជាគរឧបោសថ ឱ្យបានរាល់ខែទាំងអស់ពុំបាន ឬថានឹងរក្សាទៅក៏បានដែរ តែថាពុំបានគ្រប់គ្រាន់បរិបូណ៌ទៅតាម កំណត់នៃថ្ងៃឧបោសថកាល មានឱកាសល្មមរក្សាបានតែត្រឹម ១ បក្ខឬ ២ បក្ខជាដើមប៉ុណ្ណោះ ។

បុ. ឧបោសថមានតែ២ យ៉ាងប៉ុណ្ណោះទេ គឺបកតិឧបោសថ ១, បដិជាគរឧបោសថ១,

ចុះបាដិហារិយឧបោសថនោះកើតមានពីត្រឹមណាមក ? ព្រះអង្គទ្រង់ ប្រារព្ធនឹងបុគ្គលណា ? បុគ្គលនោះឈ្មោះអ្វី ?

វិ. ព្រះអង្គទ្រង់ប្រារព្ធចំពោះនាងឧត្តរាទេវធីតា ព្រោះនាង

រក្សានូវបកតិឧបោសថ នឹងបដិជាគរឧបោសថគ្រប់ថ្ងៃឧបោសថកាល រាល់ៗខែទាំងអស់ពុំបាន នាងក៏លះបង់នូវទិព្វសម្បត្តិក្នុងឆ្នាំមួយ បាន ចូលមកព្រោះនាងរក្សាឧបោសថគ្រប់ៗថ្ងៃឧបោសថកាលទាំងអស់ព្រម ទាំងបានប្រកាសនូវសេចក្តីជ្រះថ្លារបស់ខ្លួនចំពោះព្រះភក្រ្ត ព្រះមាន ព្រះភាគជាម្ចាស់ ព្រះអង្គក៏ទ្រង់សំដែងសរសើរអានិសង្សនេះ ចំពោះ នាងដែលបានសមាទានរក្សានូវឧបោសថនោះថា: នាងត្រូវបានផល ច្រើនណាស់ទើបបានមានឈ្មោះថាបាដិហារិយបក្ខឧបោសថចាប់ដើម តាំងពីត្រឹមកាលនោះដរាបមកដល់ឥឡូវនេះឯង ។

បុ. បាដិហារិយបក្ខឧបោសថនោះមានឈ្មោះដូចម្តេច ? ប្រែ ថាដូចម្តេច ?

វិ. មានឈ្មោះថានិព្វទ្ធុបោសថ ប្រែថាឧបោសថជាប់មិនដាច់គឺ គប្បីទទួលសមាទានរាល់ថ្ងៃ ដែលលោកបានកំណត់ទុកថាជាថ្ងៃឧបោ- សថកាលទាំងប៉ុន្មាន នឹងលុះបង់ចោលថ្ងៃណាមួយពុំបានឡើយ ។

បុ. បាដិហារិយឧបោសថនោះតើលោកកំណត់ប៉ុន្មានខែ ? គឺ ខែអ្វីខ្លះ ?

រ. លោកសំដែងដោយន័យមានប្រការផ្សេងៗ ប៉ុន្តែបើតាមក្នុងធម្មិកសូត្រទុតិយវគ្គនៃសុត្តនិបាត លោកកំណត់៥ខែ គឺខែអាសាធ១, ស្រាពណ៍១, ភទ្របទ១, អស្សុជ១, នឹងខែកត្តិក១ ។

ន័យមួយវិញទៀតក្នុងរាជសូត្រលោកពោលថា :

**តេន រាជសុត្តវណ្ណនាយំ បាដិហារិយបក្ខោ នាម អន្តោវស្សេ តេមាសំ និពទ្ធុបោសថោ តស្មិំ អសក្កោន្តស្ស ទ្វិន្នំ បវារណានំ អន្តរេ ឯកមាសំ និពទ្ធុបោសថោ តស្មិំ អសក្កោន្តស្ស បឋមបវារណតោ បដ្ឋាយ ឯកោ អឌ្ឍមាសោ បាដិហារិយបក្ខោយេវ នាមាតិ វុត្តំ ។**

(ប្រែថា) ព្រោះហេតុនោះ បាដិហារិយបក្ខ លោកពោលហើយក្នុងរាជសូត្រថា "ឧបោសថបុគ្គលរក្សាជានិច្ចអស់ខែបីខាងក្នុង នៃរដូវភ្លៀង បើបុគ្គលមិនអាចរក្សាអស់ប៉ុណ្ណោះទេ ត្រូវរក្សាជានិច្ចអស់១ខែ ត្រង់ចន្លោះបវារណាទាំងពីរ បើបុគ្គលមិនអាចរក្សាអស់ប៉ុណ្ណោះទៀតទេ ត្រូវរក្សាអស់១ខែ ឬកន្លះខែ ចាប់តាំងពីថ្ងៃបវារណាជាដំបូង (ការរក្សានេះ) ហៅថា បាដិហារិយឧបោសថ ។

ក្នុងដីកាវាជសូត្រលោកពោលថា **និពទ្ធុបោសថោ សំវច្ឆរេ សំវច្ឆរេ បដិប្បដិហារិតព្វតោ បវត្តេតព្វតោ បាដិហារិយបក្ខោ នាម ។**

(ប្រែថា)ឧបោសថជាប់មិនដាច់ លោកហៅថា បាដិហារិយបក្ខ ព្រោះបុគ្គលត្រូវរក្សារឿយៗ នឹងត្រូវប្រព្រឹត្តទៅរាល់ៗឆ្នាំ ។

ពាក្យទាំងប៉ុន្មានដែលបានអធិប្បាយមកនេះ បើសប្បុរសទាំងឡាយចូលចិត្តនូវសេចក្តីត្រង់ណា ក៏គប្បីកាន់យកសេចក្តីនោះចុះ ។

បុ. បាដិហារិយឧបោសថក្តី បកតិឧបោសថក្តី បដិជាគរឧបោសថក្តី ដូចគ្នាឬផ្សេងគ្នា ? ព្រោះហេតុអ្វី ?

វិ. ដូចគ្នាមិនផ្សេងគ្នាទេថ្ងៃបកតិឧបោសថកាលក៏នៅជាថ្ងៃបកតិឧបោសថដដែល ថ្ងៃបដិជាគរឧបោសថកាល ក៏នៅជាថ្ងៃបដិជាគរដដែលឯថ្ងៃនោះមិនប្លែកគ្នាទេ ប្លែកតែត្រង់តាំងចេតនារួមគ្នា កំណត់ថា ៥ខែ ឬ៤ខែឬ៣ខែ មិនឱ្យខ្វះឬលើសថ្ងៃដែលជាបាដិហារិយឧបោសថកាលណាមួយប៉ុណ្ណោះ ដូចមានសំដែងក្នុងឧត្តរាវិមានវណ្ណនាថា:

**បាដិហារិយបក្ខញ្ចាតិ ឧបនិហរណកបក្ខញ្ច ចាតុទ្ទសី**

**បញ្ចទសី អដ្ឋមីនំ យថាកមំ អាទិតោ អន្តតោច បក្ខគមនាគមនវសេន ឧបោសថសីលស្ស បដិជគ្គនកបក្ខញ្ច តេរសី បាដិបទសត្តមី នវមីសុចាតិ អត្ថោ ៕**

(ប្រែថា) បាដិហារិយបក្ខនោះ គឺអស់ឧបនីហរណបក្ខ គឺបក្ខសំរាប់នាំចូលនឹងបក្ខសម្រាប់នាំចេញផង, អស់បដិជគ្គនកបក្ខ គឺបក្ខខាងបដិជាគរឧបោសថដោយអំណាចថ្ងៃទទួលនឹងថ្ងៃជូនទាំងខាងដើមនឹងខាងចុងតាមលំដាប់នៃថ្ងៃ១៤កើត ១៤រោច,១៥កើត ១៥រោច, ៨កើត,៨រោច ផង គឺ ថៃទី១៣កើត,១៣រោច,១រោច,៧កើត,៧រោច, ៩កើត,៩រោច ។

អធិប្បាយថា : ក្នុងផុណ្ណបក្ខនឹងកាឡបក្ខ គឺចំណែកខាងខ្នើតនឹងខាងរនោចទាំងពីរនេះឧបោសថកាលមានតែ១៣ ថ្ងៃគឺ : បកតិឧបោសថកាល ៦ ថ្ងៃ គឺថ្ងៃ៨កើត, ៨រោច, ១៤កើត, ១៤រោច, ១៥កើត, ១៥រោច ។ ថ្ងៃបដិជាគរឧបោសថកាលមាន៧ថ្ងៃគឺ១រោច, ៧កើត,៧រោច,៩កើត,៩រោច,១៣កើត,១៣រោច,ក្នុងខែមួយៗ ត្រូវជា ១៣ថ្ងៃគត់រួមមកទាំងអស់ឈ្មោះបាដិហារិយឧបោសថកាល ។

ថ្ងៃដែលទំនេរពីថ្ងៃឧបោសថទាំងអស់១៧ថ្ងៃ បើខែខ្វះថយមក ១៦ថ្ងៃវិញជាថ្ងៃត្រូវរក្សាបញ្ចសីលក្នុងសម័យជាន់នោះ ។

ព្រោះហេតុដូច្នេះហើយ បានជាព្រះសិរិមង្គលាចារ្យលោក សំដែងកំណត់កាលបញ្ជាក់សេចក្តីថែមមកទៀតថា :

**បញ្ចមីអាទយោ មាសស្ស អដ្ឋទិវសា បកតិឧបោសថស្ស តេសមាទិអន្តភូតាច ចតុត្ថី ឆដ្ឋីអាទយោ ឯកាទស បដិជា-គរុបោសថស្ស សកលាបិ វស្សិកមាសា បាដិហារិយុបោសថស្ស កាលោតិ និដ្ឋមេត្ថ គន្តព្វំ ។**

(ប្រែថា) ក្នុងមួយខែមាន៨ថ្ងៃ មានបញ្ចមីជាដើម ជាកាលនៃបកតិឧបោសថ ថ្ងៃទាំងឡាយ១១មានថ្ងៃចតុត្ថីនឹងថ្ងៃឆដ្ឋីជាដើម ជាខាងដើមនិងខាងចុងនៃថ្ងៃបកតិឧបោសថកាលនោះ ជាកាលនៃបដិជាគរឧបោសថ ខែទាំងឡាយប្រកបដោយរដូវភ្លៀងទាំងអស់ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ជាកាលនៃបាដិហារិយឧបោសថដោយពិត ។

បុ. កាលដែលព្រះសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ ថ្ងៃឧបោសថកាលមានប៉ុន្មាន ? ចូលបញ្ជាក់ឱ្យច្បាស់លាស់មកមើល

វ. បញ្ជាក់សេចក្ដីឱ្យឃើញច្បាស់ថា : កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់គង់ព្រះជន្មនៅឡើយ ថ្ងៃឧបោសថកាលមានតែ ១៣ថ្ងៃប៉ុណ្ណោះទេ គឺថ្ងៃបកតិឧបោសថ ៦ថ្ងៃ, បដិជាគរឧបោសថ ៧ថ្ងៃក្នុងខែមួយ ។

ប. ដែលបន្ថែមថ្ងៃឧបោសថមកទៀត តើខាងក្រោយឬមុនថ្ងៃដែលព្រះអង្គបរិនិព្វាន ? សេចក្ដីយល់របស់ព្រះអរហន្តក្នុងសម័យជាន់នោះដូចម្ដេច ?

វ. លុះព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅហើយ កាលជាខាងក្រោយតមក ព្រះធម្មសង្គាហកត្ថេរទាំងឡាយដែលលោកធ្វើបឋមសង្គាយនានោះ លោកក៏បានពិចារណាយល់ឃើញច្បាស់ថា: ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតថ្ងៃឧបោសថកាល .ក្នុង១ខែ៦ថ្ងៃ ដើម្បីនឹងធ្វើចិត្តឱ្យស្អាតបរិសុទ្ធ នឹងស្ដាប់ធម៌ទេសនា នឹងធ្វើចិត្តឱ្យស្អាតផុតចាកនីវរណធម៌ទាំង៥ប្រការមានកាមឆន្ទជាដើមបាន ទើបលោកយល់ថា : មិនសមតាមកាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតឱ្យស្ដាប់ធម៌ទេសនាក្នុង១ខែ៨ថ្ងៃ ហើយលោកក៏ជ្រើសរើសយកថ្ងៃបញ្ចមី

ជាថ្ងៃសមាទានន្ទូវអង្គនៃបកតិឧបោសថថែមពីរថ្ងៃទៀត រួមត្រូវជាបកតិឧបោសថមាន៨ថ្ងៃ ។

បុ. ឯបាដិហារិយឧបោសថនោះ រក្សាបានតែវស្សាវស្សាទាំង ៤ខែឬដូចម្ដេច ?

វិ. មិនមែនបានតែក្នុងវស្សាវស្សាទេ ត្រង់ពាក្យដែលលោកថា "**សកលាមិទស្សិកមាសា**" ប្រែថា ខែទាំងឡាយដែលប្រកបដោយវស្សាវស្សាទាំងអស់ខ្លះ នឹងចូលចិត្តថា រក្សាន្ទូវបាដិហារិយឧបោសថបានតែក្នុងវស្សាវស្សា ៤ ខែប៉ុណ្ណោះក៏ទេដែរ, **សកលាមិ** ប្រែថា ទាំងអស់ខ្លះឬថា ទាំងអស់ក៏បាន ពាក្យដែលលោកប្រែថា ទាំងអស់ខ្លះនោះ បានសេចក្ដីថា រក្សាន្ទូវបាដិហារិយឧបោសថអស់វស្សាវស្សាទាំង ៤ ខែក៏គួរដែរ ។

ពាក្យដែលប្រែថា ទាំងអស់ក៏បាននោះ បានសេចក្ដីថា រក្សាន្ទូវបាដិហារិយឧបោសថអស់វស្សាវស្សាទាំង ៤ ខែក៏បាន, ១ខែក៏បាន, ដូចសេចក្ដីខាងដើម ដែលបានសំដែងកំណត់កាលរួចមកហើយ ។

បុ. ឯបាដិហារិយឧបោសថនោះ ក្នុង ១ ខែ១ ត្រូវឱ្យរក្សារាល់ៗ

ថ្ងៃឬដូចម្ដេច?

វិ. មិនមែនរាល់ៗថ្ងៃទេ គឺរាល់ៗថ្ងៃឧបោសថកាលទេតើ ពាក្យដែលលោកពោលថា ខែទាំងឡាយប្រកបដោយរដូវភ្លៀងជាកាលគួរនឹងរក្សានូវបាដិហារិយឧបោសថទាំងអស់ក៏ឃើញច្បាស់ថា ហាក់ដូចជា ឱ្យរក្សានូវបាដិហារិយឧបោសថក្នុងខែនីមួយៗរាល់ៗថ្ងៃទាំងអស់ បានជាមានពាក្យគេចិអាចារ្យស័ង្ស័យដូច្នេះថា រក្សានូវឧបោសថក្នុងថ្ងៃណាមួយក៏បានឥតទាស់ខុសអ្វីឡើយ ឬថានឹងរក្សារាលៗថ្ងៃទៅនោះក៏បានដែរ តំ អយុត្តំ ឯពាក្យដែលគេចិអាចារ្យពោលដូច្នេះនោះមិនគួរសោះ ឡើយព្រោះថាជាហេតុនឹងនាមថ្ងៃឧបោសថកាល ដែលលោកបានកំណត់មកទាំងប៉ុន្មាននោះ ឱ្យខុសស្រឡះឥតប្រយោជន៍ទាំងអស់ដូចបាលីថា :

**ឯវញ្ចរិ សតិ ចាតុទ្ទសីតិអាទិនិយមោ និរត្ថកោ សិយា**

កាលបើពាក្យគេចិអាចារ្យពោលមកយ៉ាងនេះពិតប្រាកដមែន ការកំនត់ថ្ងៃឧបោសថកាលទាំងប៉ុន្មាន មានថ្ងៃចាតុទ្ទសីជាដើម ដែលលោកពោលទុកក្នុងឧត្តរវិមានវណ្ណនាថាជាសត្រូវរក្សាបាដិហារិយឧបោសថ

នោះ និង ត្រឡប់ទៅជាឥតប្រយោជន៍វសាវរបង់ ។

**នចេស និរុត្តោ** ឯការកំណត់ថ្ងៃទាំងឡាយមានថ្ងៃចាតុទ្ទសីជាដើមនោះ មិនមែនជាថ្ងៃឥតប្រយោជន៍ទេ គឺជាថ្ងៃមានប្រយោជន៍សំខាន់ណាស់ គឺឱ្យរក្សារាល់ៗ ឧបោសថកាល ដែលជាកាលនៃបាដិហារិយឧបោសថប៉ុណ្ណោះទេតើ ។

បុ. បើដូច្នោះ ថ្ងៃដែលបានកំណត់មកទាំងប៉ុ ន្មាននឹងចូលចិត្តសេចក្តីយ៉ាងណា? ចូរអធិប្បាយ

វិ. នឹងចូលចិត្តសេចក្តីថា កេចិអាចារ្យសង្ស័យពីថ្ងៃបកតិឧបោសថអំពីថ្ងៃបដិជាគរឧបោសថដូច្នេះទៅវិញនោះមិនគួរទេ ព្រោះព្រះអដ្ឋកថាចារ្យ លោកបានពោលកំណត់ថា ថ្ងៃបកតិឧបោសថទាំង ៨ថ្ងៃមានថ្ងៃបញ្ចមីជាដើម, ថ្ងៃបដិជាគរឧបោសថ១១ថ្ងៃ មានថ្ងៃចតុត្ថីនឹងឆដ្ឋីជាដើម ប៉ុណ្ណោះជាថ្ងៃបាដិហារិយឧបោសថកាល ហើយឱ្យត្រូវតាមខែទៀតផង ។

បុ. ហេតុនោះ ឧបាសក-សិកាទាំងឡាយគប្បីរក្សានូវបាដិហារិយឧបោសថនោះ ក្នុងក្ខមួយៗរាល់ៗថ្ងៃទៅឬដូម្តេច ?

វិ. ឧបោសកៈសិកាទាំងឡាយគប្បីចូលចិត្តឱ្យជាក់ច្បាស់ចុះថា រក្សានូវបាដិហារិយឧបោសថនេះក្នុងបក្ខមួយៗនឹងរក្សារាល់ៗថ្ងៃទៅក៏ទេដែរ,គឺរក្សាតែថ្ងៃដែលបានសំដែងកំណត់ថា ជាថ្ងៃឧបោសថក្នុងខែមួយរក្សានូវឧបោសថ១៩ថ្ងៃគត់ គឺថ្ងៃបកតិឧបោសថ៨ថ្ងៃ ថ្ងៃបដិជាគរឧបោសថ ១១ ថ្ងៃត្រូវឱ្យរក្សាគ្រប់ថ្ងៃទាំងអស់នឹងលះបង់ថ្ងៃណាមួយបានឡើយទើបបានឈ្មោះថា បាដិហារិយបក្ខឧបោសថដោយពិត ។

បុ. ចុះការរក្សាបាដិហារិយឧបោសថនោះមានគុណានិសង្សដូចគ្នានឹងរក្សាបកតិឧបោសថនឹងបដិជាគរឧបោសថដែរឬផ្សេងគ្នា ? ព្រោះហេតុអ្វី ?

វិ. មានគុណានិសង្សវិសេសខុសគ្នាមិនដូចគ្នាទេ, ព្រោះថាការរក្សានូវបាដិហារិយឧបោសថ គឺងរឹងយ៉ាងឧក្រិដ្ឋមានច្បាប់បញ្ញត្តហាមប្រាមផ្តាច់ថា កាលបើបុគ្គលបានរក្សានូវបាដិហារិយបក្ខឧបោសថហើយត្រូវរក្សាឱ្យបានគ្រប់ថ្ងៃ ឧបោសថទាំងអស់ដែលមានកំណត់កាលថាជាថ្ងៃឧបោសថទាំងប៉ុន្មានទើបបាន, តែរក្សាមិនគ្រប់កាលដែលមានកំណត់ថាជាថ្ងៃឧបោសថហើយ មិនបានឈ្មោះថាបាដិហារិយ

ឧបោសថឡើយ ។

បុ. ចុះបកតិឧបោសថ នឹងបដិជាគរឧបោសថ សុទ្ធតែមាន កំណត់ថ្ងៃទាំងអស់ឬអ្វីបើរក្សាមិនបានគ្រប់ចំនួនថ្ងៃ ដែលលោកបាន កំណត់មកទាំងប៉ុន្មានទេ តើនឹងកើតឡើងជាឧបោសថដែរឬដូចម្ដេច?

វិ. លោកបានកំណត់ថ្ងៃជាទៀងទាត់, ឯបកតិឧបោសថមាន កំណត់កាល៨ថ្ងៃ បដិជាគរឧបោសថកំណត់កាល១១ថៃ ក្នុងមួយខែក៏ ពិតមែនហើយតែមិនមានច្បាប់បញ្ញាត្ត នឹងហាមដាច់ខាតថា : ត្រូវតែ ទទួលសមាទាននូវអង្គនៃបកតិឧបោសថ ឱ្យបានគ្រប់ថ្ងៃឧបោសថដែល លោកកំណត់កាលក្នុងមួយខែៗនោះទេ ទោះបីរក្សាក្នុងខែ ១ ឱ្យគ្រប់ ថ្ងៃទាំងអស់ទៅក៏បាន រក្សាតែ៨ថ្ងៃក៏បាន រក្សាតែ២ថ្ងៃក៏បាន,រក្សាតែ មួយថ្ងៃក៏បាន តាមសមគួរដល់សទ្ធារបស់អ្នករក្សា ។

បុ. ឧបោសថនោះ តើមានប៉ុន្មានយ៉ាងតទៅទៀត ?

វិ. ឧបោសថនោះមាន៣យ៉ាងទៀតគឺ :

**១-គោបាលឧបោសថ, ២-និគណ្ឋឧបោសថ, ៣-អរិយុ-ឧបោសថ** រួមត្រូវជា៣យ៉ាងដូច្នេះ ។

បុ. ឯគោបាលឧបោសថនោះ តើរក្សាដូចម្តេច ? ចូរអធិប្បាយ

វិ. ឯគោបាលឧបោសថនោះ រក្សាឧបោសថដូចជានាយគង្វាលគោ, អធិប្បាយជាបុគ្គលរក្សានូវឧបោសថ ដូចជានាយគោបាលដែលស៊ីឈ្នួលឃ្វាលគោឱ្យអ្នកដទៃ កៀងគោឱ្យទៅកាន់ទីដែលមានទឹកនឹងស្មៅជាដើមទន្ទឹងឱ្យតែដល់ពេលហើយ នឹងកៀងមកប្រគល់ឱ្យម្ចាស់គេវិញទារយកតែថ្លៃឈ្នួលប៉ុណ្ណោះឯងសេចក្តីនេះមានឧបមាយ៉ាងណាមិញ ចំណែកខាងបុគ្គលដែលរក្សានូវឧបោសថនោះ ទន្ទឹងឱ្យតែអស់កាលឧបោសថហើយនឹងអាលបរិភោគនូវអាហារភោជន នឹងបរិភោគនូវកាមគុណមានប្រការៈផ្សេងៗ តាមតែចំណង់ចិត្តរបស់ខ្លួនកាលពីថ្ងៃមុន យ៉ាងនេះឈ្មោះថាគោបាលឧបោសថមានអានិសង្សតិច មានពន្លឺរស្មីមិនសូវរុងរឿងឡើយ ដូចជានាយគង្វាលគោដូច្នោះឯង ។

បុ. និគណ្ឋឧបោសថនោះ តើឧបោសថដូចម្តេច? ចូរអធិប្បាយ

វិ. ឯនិគណ្ឋឧបោសថនោះ រក្សាឧបោសថដូចជាឧបោសថនិគ្រន្ថ

អធិប្បាយថា : ពួកនិគ្រន្ថក្តិរិយរក្សាមានកំណត់ខែត្រ-ដែនរបស់

ខ្លួនដូចយ៉ាងកំណត់ថាសត្វដែលនៅទិសខាងកើត ឆ្ងាយអំពី១០០ យោជន៍ទៅ, ខាងត្បូងឆ្ងាយពី១០០យោជន៍ទៅ, ខាងលិចឆ្ងាយពី១០០ យោជន៍ទៅ, ខាងជើងឆ្ងាយពី១០០យោជន៍ទៅ, គេវៀរមិនសម្លាប់ សត្វទាំងអស់នោះ ដូច្នេះឈ្មោះថានិគណ្ឋឧបោសថ ។ បើពួកឧបាសក-សិកាណារក្សាបែបនេះ ឈ្មោះថានិគណ្ឋឧបោសថមិនមានអានិសង្ស ឡើយ ។

បុ. ឯអរិយឧបោសថនោះ តើដូចម្តេច ?

វិ. ឯអរិយឧបោសថនោះ បានដល់ឧបោសថរបស់ព្រះអរិយព្រះ អរិយបុគ្គលគឺលោករក្សានូវឧបោសថ កំចាត់បង់នូវឧបក្កិលេសឱ្យ បរិសុទ្ធស្អាតឱ្យប្រាសចាកសេចក្តីសៅហ្មង ពីខន្ធសន្តាន ។ លោកលះ បង់នូវកិលេសណាហើយ មិនត្រឡប់មកកាន់កិលេសនោះវិញ , ឈ្មោះថាអរិយឧបោសថ បើឧបាសក-សិការក្សាបែបនេះ ឈ្មោះថាអរិយឧបោសថរមែងមានអានិសង្សច្រើនយ៉ាងក្រៃលែង ។

បុ. អង្គនៃឧបោសថមានប៉ុន្មានទ្បានគឺអ្វីខ្លះ ? ចូលរាប់

វិ. មាន៨ សមដូចព្រះអង្គសំដែងបញ្ញត្តទុកមកក្នុងឧបោសថ

សូត្រ ក្នុងគម្ពីរតិកង្គុត្តរនិកាយថា .

បាណំ ន ហនេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចរិយា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ
មាលំ ន ធារេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំវ សយេថ សន្ថតេ
ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ ។

(ប្រែថា) បុគ្គលមិនត្រូវសម្លាប់សត្វដោយខ្លួនឯង, ទាំងមិនត្រូវប្រើគេឱ្យសម្លាប់១, មិនត្រូវលួចទ្រព្យគេដោយខ្លួនឯង ទាំងមិនត្រូវប្រើគេឱ្យលួច១, ត្រូវវៀរចាកកិរិយាប្រព្រឹត្តធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម១, មិនត្រូវពោលពាក្យកុហក១, មិនត្រូវផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យ១, មិនត្រូវបរិភោគអាហារក្នុងវេលាវិកាល១ មិនត្រូវទ្រទ្រង់នូវផ្កាកម្រងនឹងគ្រឿងក្រអូបផ្សេងៗ១ មិនត្រូវដេកឬអង្គុយលើ

គ្រឿងមិនគួរឬមិនត្រូវដេកឬអង្គុយលើធរណី ជំក្រាលដោយគ្រឿងកម្រាលដ៏មិនគួរ១ ។

សេចក្ដីដូចបានសំដែងមកនេះ លោកអ្នកប្រាជ្ញទាំងឡាយមានព្រះអរហំសម្មាសម្ពុទ្ធជាដើម លោកដល់នូវទីបំផុតនៃសេចក្ដីទុក្ខបានសំដែងនូវឧបោសថ ដែលប្រកបដោយអង្គទាំង៨ប្រការនេះ (បញ្ញត្តទុកមកដរាបដល់កាលឥឡូវនេះដោយពិត) ។

បុ. បាណាតិបាតសិក្ខាបទ ប្រែដូចម្ដេច ?

វិ. ប្រែថាវៀរចាកនូវកិរិយាសម្លាប់សត្វ ។

បុ. បាណាតិបាតសិក្ខាបទ មានអង្គប៉ុន្មាន? អ្វីខ្លះ?

វិ. មានអង្គ៥គឺ :

១-**បាណោ** សត្វមានជីវិត

២-**បាណសញ្ញិតា** សេចក្ដីដឹងថាសត្វមានជីវិត ។

៣-**វធកចិត្តំ** ចិត្តគិតនឹងសម្លាប់

៤-**ឧបក្កមោ** ព្យាយាមនឹងសម្លាប់

៥-**តេនមរណំ** សត្វស្លាប់ដោយព្យាយាមនោះ

បើមិនប្រកបដោយអង្គទាំង៥នេះទេ មិនឈ្មោះថាដាច់បាណា-តិបាតឡើយ ។

បុ. បុគ្គលអ្នកប្រព្រឹត្តកន្លងនូវសិក្ខាបទទាំងឡាយមានទោសដែរឬមិនមានទេ? បើមានទោសសុទ្ធតែធ្ងន់ទាំងអស់ ឬ សុទ្ធតែស្រាលទាំងអស់ឬមានធ្ងន់មានស្រាល? ព្រោះហេតុអ្វី?

វិ. ការប្រព្រឹត្តកន្លងនូវសិក្ខាបទទាំងឡាយ រមែងមានទោស, ប៉ុន្តែមិនមែនមានទោសធ្ងន់ទាំងអស់ទេ, មិនមែនស្រាលទាំងអស់ទេ មានធ្ងន់មានស្រាលព្រោះតាមកម្លាំងព្យាយាមនឹងរូបសត្វ ។

បុ. ការប្រព្រឹត្តិកន្លងគឺសម្លាប់សត្វដូចម្តេចមានទោសស្រាល ? សម្លាប់សត្វដូចម្តេចមានទោសធ្ងន់? ព្រោះហេតុអ្វី ?

វិ. សម្លាប់សត្វតូចមានទោសស្រាល, សម្លាប់សត្វធំមានទោសធ្ងន់ ព្រោះថាសត្វតូចមានព្យាយាមតិច សម្លាប់សត្វធំមានព្យាយាមច្រើន ។

បុ. ពាក្យថាសត្វក្នុងទីនេះ សំដៅយកតែសត្វតិរច្ឆាន ឬសំដៅយកមនុស្សជាតិដែរ

វិ. សត្វក្នុងទីនេះ សំដៅយកទាំងសត្វតិរច្ឆានទាំងមនុស្ស ។

ឞុ. ចុះការប្រព្រឹត្តិកន្ទង គឺសម្លាប់សត្វនឹងមនុស្សធ្ងន់-ស្រាល ដូចគ្នា ឬ ខុសគ្នា ? ព្រោះហេតុអ្វី ?

វិ. សម្លាប់សត្វតិរច្ឆានមានទោសស្រាល សម្លាប់មនុស្សមានទោសធ្ងន់ ព្រោះថាសត្វតិរច្ឆានជាអភព្វរូបជាសត្វមិនគួរទទួលមគ្គផលជាន់ខ្ពស់បាន,ទោះបីបានស្តាប់ធម៌ទេសនាអំពីពុទ្ធឱស្ឋហើយ មានសេចក្តីជ្រះថ្លាមុតមាំយ៉ាងណា ក៏មិនអាចលុះមគ្គផលជាន់ខ្ពស់បាន ឯមនុស្សជាតិអាចទទួលមគ្គផលបាន ។

ឞុ. ចុះបុគ្គលបានប្រព្រឹត្តធ្វើនូវអំពើបាណតិបាតនេះហើយ លុះបែកធ្លាយរាងកាយទៅកាន់បរលោក ទទួលរងនូវសេចក្តីទុក្ខក្នុងទីណាខ្លះ ? ចូរអធិប្បាយ

វិ. ទៅទទួលរងទុក្ខក្នុងអបាយភូមិទាំងបួន

អធិប្បាយថា : បុគ្គលនោះឯងស្លាបទៅត្រូវទទួលរងនូវសេចក្តីទុក្ខក្នុងនរកអស់កាលជាយូរអង្វែង លុះរួចអំពីនរកនោះមកហើយ ក៏បានមកកើតជាប្រេត អសុរកាយ ជាសត្វតិរច្ឆាន រួចអំពីនោះមកកើតជាមនុស្សមានរូបរាងកាយនោះអាក្រក់រកអ្វីប្រៀបផ្ទឹមពុំបាន ឯរោគា

ព្យាធិ រមែងតែងបៀតបៀនបុគ្គលនោះជាច្រើន គឺមានអាយុនោះក៏ ឯអំពើបាណាតិបាតនេះ ឱ្យផលឆាប់រហ័សជាងកម្មទាំងពួង មានទុ ផលជាទិដ្ឋធម្មវេទនីយកម្មក្នុងជាតិនេះក៏សឹងមាន, បើបុគ្គលឯណ មួយបានវៀរលែងមិនធ្វើនូវអំពើបាណាតិបាតនេះបានហើយ, បុគ្គ នោះលុះស្លាប់ទៅហើយ ទៀងតែនឹងបានសោយសម្បត្តិសុខ កើ ឡើងក្នុងជាតិណាៗរូបក៏ល្អ រោគាព្យាធិ ក៏មិនសូវមាន អាយុក៏វែ តាមកាលកំណត់អាយុក្ខ័យ ។

បុ. អទិន្នាទានសិក្ខាបទនោះ ប្រែថាដូចម្ដេច ?

វិ. ប្រែថា : វៀរបង់នូវការលួចឆក់ប្រវ័ញ្ចន៍នូវទ្រព្យនៃបុគ្គ ដទៃ ។

បុ. លួចដូចម្ដេចដែលមានទោសស្រាល ? លួចដូចម្ដេចមា ទោសធ្ងន់ ?

វិ. លួចទ្រព្យមានតម្លៃតិចមានទោសស្រាល, លួចទ្រព្យមា តម្លៃច្រើនមានទោសធ្ងន់, បើទុកជាទ្រព្យនោះមានតម្លៃស្មើគ្នា, អ្នកមានគុណវិសេសតិច ទោសនោះក៏ស្រាល, អ្នកមានគុណវិសេ

ច្រើនទោសនោះក៏ធ្ងន់ ។ បើលួចដោយព្យាយាមយំភ្លៀវក្លាវ័ងវឹតតែមានទោសនោះធ្ងន់ទៅទៀត ។

ប៉ុ. អទិន្នាទានសិក្ខាបទមានអង្គប៉ុន្មាន ?

វិ. មានអង្គ៥គឺ :

១.បរបរិគ្គហឹតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

២.បរបរិគ្គហិតសញ្ញិតា សំគាល់ដឹងថា ជាទ្រព្យមានម្ចាស់គេហួងហែងរក្សា

៣.ថេយ្យចិត្តំ ចិត្តចង់លួចទ្រព្យដែលម្ចាស់គេហួងហែងរក្សា

៤.ឧបក្កមោ ព្យាយាមនឹងលួច

៥.តេនហារណំ លួចយកទៅបានដោយសេចក្តីព្យាយាមនោះ ។

ប៉ុ. បើមិនប្រកបព្រមដោយអង្គទាំង៥ នេះទេ តើត្រូវអទិន្នាទានដែរឬ?

វិ. បើមិនប្រកបព្រមដោយអង្គទាំង៥ នេះទេ មិនត្រូវអទិន្នាទានឡើយ ។

ប៉ុ. បើបុគ្គលណាមួយបានប្រព្រឹត្តកន្លងអទិន្នាទានសិក្ខាបទនេះ

ហើយ លុះស្លាប់ទៅនឹងបានទៅរងសេចក្តីទុក្ខលំបាកយ៉ាងដូចម្តេចខ្លះ?

វិ. បុគ្គលណាមួយបានប្រព្រឹត្តកន្លងអទិន្នាទានសិក្ខាបទនេះ ហើយ លុះស្លាប់ទៅៗរងទុក្ខក្នុងនរកអស់កាលជាយូរអង្វែង, លុះរួចអំពីនរកមកហើយ ដោយសេសសល់ផលកម្មបានកើតជាសត្វតិរច្ឆានរកចំណីអាហារគ្រាន់តែនឹងបរិភោគក៏បានដោយកម្រ, បើនឹងបានទៅកើតជាមនុស្សក៏កើតក្នុងត្រកូលដ៏ថោកទាបខ្សត់ខ្សោយ ទ្រព្យសម្បត្តិសូម្បីតែអាហារសម្រាប់បរិភោគក៏មិន ដែលបានឆ្អែតស្កប់ស្កល់នឹងគេ, ឯទ្រព្យសម្បត្តិដែលខ្លួនរកបានមកបន្តិចបន្តួច ក៏តែងតែវិនាសទៅដោយចោរលួចភ្លើងឆេះ កណ្តៀរកោរកណ្តុរកាត់ជាដើម រមែងរងទុក្ខវេទនាយ៉ាងដូច្នេះនេះ គឺច្រើនជាតិណាស់ នឹងត្រារាប់ថាប៉ុណ្ណេះប៉ុណ្ណោះពុំបាន ។

បុ. អព្រហ្មចរិយសិក្ខាបទ ប្រែថាដូចម្តេច ?

វិ. ប្រែថាវៀរចាកនូវកិរិយាប្រព្រឹត្តកន្លងនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

បុ. ធម៌ដូចម្តេចដែលហៅថា មេថុន ?

វិ. ធម៌ដែលហៅថា មេថុននោះ គឺធម៌របស់អសប្បុរស ធម៌របស់ អ្នកស្រុក ធម៌របស់មនុស្សដ៏ថោកទាប ជាអំពើដែលជនពីរនាក់ តែងរួមគ្នាក្នុងទីកំបាំងនេះឯងហៅថា មេថុន ។

បុ. កាមេសុមិច្ឆាចារសិក្ខាបទ នឹងអព្រហ្មចរិយសិក្ខាបទ ផ្សេងគ្នា ឬដូចគ្នា ? ព្រោះហេតុអ្វី ?

វិ. ផ្សេងគ្នា គឺកាមេសុមិច្ឆាចារ លោកឱ្យវៀរចាកស្រី២០ជំពូក, អព្រហ្មចរិយលោកឱ្យវៀរចំពោះទ្វារមគ្គទាំង៣០ អស់យប់ ១ ថ្ងៃ១ ព្រោះថាសិក្ខាបទទាំងពីរនេះ បើបុគ្គលប្រព្រឹត្តកន្លងហើយ រមែងមានទោសផ្សេងគ្នា, កាមេសុមិច្ឆាចារសិក្ខាបទ មានទោសជាធម្មតាលោក ទោះបីបានសមាទានក៏ដោយ មិនបានសមាទានក៏ដោយ ឱ្យតែប្រព្រឹត្តកន្លងមិនផុតទោសឡើយ, ឯអព្រហ្មចរិយសិក្ខាបទត្រាតែខ្លួនបានសមាទានហើយព្រប្រព្រឹត្តកន្លងទើបមានទោស ព្រោះសិក្ខាបទនេះមានទោសដោយកន្លងបញ្ញត្តិ ។

បុ. ស្រី២០ ជំពូកនោះតើអ្វីខ្លះ ?

វិ. ស្រី២០ ជំពូកនោះគឺ

**១.មាតុរក្ខិតា** ស្រីដែលមានមាតាថែរក្សា

**២.បិតុរក្ខិតា** ស្រីដែលបិតាថែរក្សា

**៣.មាតាបិតុរក្ខិតា** ស្រីដែលមានមាតាបិតាថែរក្សា

**៤.ភាតុរក្ខិតា** ស្រីដែលមានបងប្រុសឬប្អូនស្រីថែរក្សា

**៥.ភគិនិរក្ខិតា** ស្រីដែលមានបងស្រីឬប្អូនប្រុសថែរក្សា

**៦.ញាតិរក្ខិតា** ស្រីដែលញាតិថែរក្សា

**៧.គោត្តរក្ខិតា** ស្រីដែលមានគោត្តថែរក្សា(អ្នកមានសែដូចគ្នាថែរក្សា)

**៨.ធម្មរក្ខិតា** ស្រីដែលមានសង្ឃថែរក្សា. ស្រីទាំង៨ជំពូកនេះ បើបុរសណាមួយសេពហើយ ត្រូវទោសកាមេសុមិច្ឆាចារ តែបុរសឯស្រីមិនត្រូវទោសអ្វីឡើយ

**៩.សារក្ខា** ស្រីដែលមានប្តីថែរក្សា

**១០.សបរិទណ្ឌា** ស្រីដែលមានស្តេចដាក់អាជ្ញាថាយកធ្វើជាទេពី

**១១.ធនក្កីតា** ស្រីដែលគេទិញដោយទ្រព្យ

**១២. ឆន្ទវាសិនី** ស្រីដែលនៅដោយស្ម័គ្រចិត្តគ្នានឹងគ្នា

**១៣. ភោគវាសិនី** ស្រីដែលនៅដោយសម្បត្តិ

**១៤. បដវាសិនី** ស្រីដែលគេផ្ចោបដៃជាមួយនឹងបុរសហើយជ្រលក់ទៅក្នុងពាងទឹក ឬផ្តិលទឹក

**១៦. ឱភតចុម្ពដា** ស្រីដែលគេដាក់ទ្រនូលពីក្បាល គឺស្រីអ្នករកឧសជាជាដើម

**១៧. ទាសី ច ភរិយាច** ស្រីដែលជាទាសីគេផងជាភរិយាគេផង គឺស្រីដែលជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា

**១៨. កម្មការីភរិយា** ស្រីដែលជាកូនឈ្នួលរបស់បុរសណាមួយហើយបុរសនោះយកធ្វើជាភរិយា

**១៩. ធជាហដា** ស្រីនោះគេចាប់ពីក្នុងទ័ព

**២០. មហុត្តិកា** ស្រីដែលនៅជាមួយគ្នាជាប្តីប្រពន្ធ តែមួយវេលា ស្រីទាំង ១២ នេះ បើបុរសណាមួយទៅសេពហើយត្រូវទោសកាមេសុមិច្ឆាចារទាំងបុរសនឹងស្រី ។

បុ. ស្រីទាំង៨ជំពូកនេះ បើបុរសណាមួយទៅសេពហើយត្រូវកាមេសុមិច្ឆាចារ ចុះហេតុអ្វីចំណែកខាងស្រីក៏មិនត្រូវផង ? ចូរអធិប្បាយមកមើល

វិ. ឯស្រីទាំង៨ជំពូកនោះ បានជាត្រូវទោសក្នុងកាមេសុមិច្ឆាចារចំពោះតែបុរសស្ត្រីមិនត្រូវ ព្រោះថា ស្រីនោះ មាតាបិតាគ្រាន់តែឃុំគ្រងរក្សាកេរ្តិ៍មារយាទខាងក្រៅៗប៉ុណ្ណោះ មិនមែនជាម្ចាស់សម្ផស្សរបស់ស្រីនោះទេ គឺថាគ្មានស្វាមីគ្រប់គ្រង បានជាលោកសំដែងថា បើបុរសណាមួយទៅសេពនឹងស្រីនោះ ត្រូវទោសក្នុងកាមេសុមិច្ឆាចារតែបុរស ឯស្ត្រីមិនត្រូវទោសឡើយ ។

ឯស្រីទាំង១២ជំពូកនេះ ដែលថាត្រូវទោសក្នុងកាមេសុមិច្ឆាចារទាំងបុរសទាំងស្រីព្រោះថា ស្រីនោះមានស្វាមីគ្រប់គ្រងថែរក្សាឈ្មោះថាលួចសម្ផស្សរបស់ស្វាមីដូច្នេះហើយបានជាលោកសំដែងថា ស្រីពួកនេះ បើបុរសណាមួយទៅសេពត្រូវកាមេសុមិច្ឆាចារទាំងបុរស់ទាំងស្ត្រីគឺស្រីនោះឈ្មោះថា លួចសម្ផស្សប្តីទៅឱ្យបុរសដទៃ ។

បុ. ទ្វារមគ្គទាំង៣០ នោះតើអ្វីខ្លះ ? ចូររាប់

វិ. ទ្វារមគ្គទាំង៣០នោះ គឺទ្វាររបស់មនុស្ស១០, អមនុស្ស១០, សត្វតិរច្ឆាន១០, មនុស្សស្រីមានទ្វារ៣, គឺ ; វច្ចមគ្គ ទ្វារធំ១, បស្សាវមគ្គ ទ្វារតូច១, មុខមគ្គទ្វារមាត់១ ; មនុស្សប្រុសមានទ្វារពីរគឺៈ វច្ចមគ្គ១, មុខមគ្គ១ ; ឧភតោព្យញ្ជនកៈ មានទ្វារ៣ដូចមនុស្សស្រី, បណ្ឌកមានទ្វារពីរដូចមនុស្សប្រុសដែរ រួបរួមត្រូវជាទ្វារមគ្គរបស់មនុស្ស១០ ។ ទ្វារមគ្គរបស់មនុស្សនោះក៏ចាត់ជាស្រីមានទ្វារ៣, ប្រុសមានទ្វារ២, ឧភតោព្យញ្ជនកៈ មានទ្វារ៣, បណ្ឌកៈមានទ្វារ ២ រួចត្រូវជាទ្វាររបស់អមនុស្ស ១០ ; ទ្វារសត្វតិរច្ឆាននោះ ក៏ចាត់ជាញីមានទ្វារ២, ឧភតោព្យញ្ជនកៈមានទ្វារ៣, សត្វបណ្ឌកៈមានទ្វារ២ រួមត្រូវជាទ្វារសត្វតិរច្ឆាន១០ ។

បុ. អព្រហ្មចរិយសិក្ខាបទនោះមានអង្គប៉ុន្មាន ?

វិ. អព្រហ្មចរិយ (១) សិក្ខាបទនោះមានអង្គ៤គឺ :

**១.សេវនចិត្តំ** វត្ថុជាទីទំលាយនូវសីលគឺទ្វារទាំង៣០, ចំពោះទ្វារណាមួយ

(១) ក្នុងព្រហ្មជាលិកាទីងកង្ខាវិតរណីមានអង្គពីរគឺសេវិតុកាមតាចិត្តំ១, មគ្គេនមគ្គប្បដិបត្តិ១ ។

**២.សេវនចិត្តំ** ចិត្តគិតនឹងសេព

**៣.តជ្ជោវាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤.មគ្គេនមគ្គប្បដិបាទនំ ញ៉ាំងមគ្គនឹងមគ្គឱ្យដល់គ្នា

បុ. បើមិនប្រកបព្រមដោយអង្គទាំង ៤ នេះ តើត្រូវទោសក្នុងអព្រហ្មចរិយសិក្ខាបទដែរឬទេ ?

វិ. បើមិនប្រកបដោយអង្គទាំង៤នេះទេមិនត្រូវទោសក្នុងអព្រ-ហ្មដោយសិក្ខាបទនេះឡើយ ។

បុ. មុសាវាទសិក្ខាបទនេះ ប្រែថា ដូចម្ដេច ?

វិ. ប្រែថា វៀរបង់នូវកិរិយាពោលនូវពាក្យកុហក ។

បុ. កុហកដូចម្ដេចមានទោសស្រាល ? កុហកដូចម្ដេចមានទោសធ្ងន់ ?

វិ. បើកុហកឱ្យខូចប្រយោជន៍អ្នកដទៃតិចមានទោសស្រាល, បើឱ្យខូចប្រយោជន៍អ្នកដទៃច្រើន ទោសនោះក៏ធ្ងន់, បើខូចប្រយោជន៍អ្នកដទៃដែលមានគុណវិសេសតិចទោសនោះក៏ស្រាល អ្នកមានគុណវិសេសច្រើន ទោសនោះក៏ធ្ងន់, បើរបស់ខ្លួនមានហើយ គេមករក

សុំក្តី-ឪក្តីកុហកថាគ្មានវិញទោសនោះក៏ស្រាល បើទៅធ្វើជាបន្ទាល់សាក្សីគេ ហើយកុហកដោយកិលេសទន់ នឹងព្យាយាមទន់ទោសនោះក៏ស្រាល បើកិលេសនឹងព្យាយាមដ៏ក្លៀវក្លា ទោសនោះក៏ធ្ងន់បើកុហកគ្រាន់នឹងសើចលេងទោសនោះក៏ស្រាល បើមិនដឹងហើយកុហកថាដឹងដឹងថា មិនដឹងវិញ មិនឃើញវិញ មិនឃើញហើយកុហកថាឃើញទោសនោះក៏ធ្ងន់ ។

បុ. មុសាវាទសិក្ខាបទនេះមានអង្គប៉ុន្មាន ?

វិ. ឯមុសាវាទសិក្ខាបទនេះមានអង្គ៤គឺ:

**១-អតច្ចំវត្ថុ** វត្ថុមិនពិត

**២-វិសំវាទនចិត្តំ** ចិត្តគិតនឹងពោលឱ្យខុស

**៣-តជ្ជោវាយាមោ** ព្យាយាមនឹងពោលឱ្យខុស

**៤-បរស្សតទត្ថវិជ្ជាននំ** ព្យាយាមពោលនូវពាក្យឱ្យអ្នកដទៃដឹងច្បាស់នូវសេចក្តីនោះ ។

បុ. បើមិនប្រកបព្រមដោយអង្គទាំង៤នេះ តើត្រូវទោសក្នុងមុសាវាទសិក្ខាបទដែរឬ ?

វិ. បើមិនព្រមដោយអង្គទាំង៤នេះទេ មិនត្រូវទោសក្នុងមុសាវាទសិក្ខាបទនេះឡើយ ។

បុ. ឯមុសាវាទសិក្ខាបទនេះ បើបុគ្គលណាមួយបានប្រព្រឹត្តធ្វើហើយ អ្នកនោះស្លាប់ទៅ នឹងបានទៅសោយទុក្ខវេទនាដូចម្តេចខ្លះ ?

វិ. បើបុគ្គលណាមួយ បានប្រព្រឹត្តកន្លងហើយ បុគ្គលនោះឯងលុះស្លាប់ទៅហើយ នឹងបាន សោយទុក្ខវេទនា ក្នុងនរកអស់កាលជាយូរអង្វែង ដោយអំណាចសេសសល់ផលកម្មត្រឡប់បានកើតជាសត្វតិរច្ឆានក្តី ជាមនុស្សក្តី មានគេកុហកបញ្ឆោតឱ្យខូចប្រយោជន៍ដូច្នេះរាល់ៗជាតិរៀងៗទៅ ។

បុ. សុរាមេរយសិក្ខាបទនេះ ប្រែថាដូម្តេច ?

វិ. ប្រែថា វៀរចាកនូវកិរិយាផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យ ។

បុ. សុរាមេរយសិក្ខាបទនេះ មានអង្គប៉ុន្មាន ?

វិ. សុរាមេរយសិក្ខាបទនោះមានអង្គ៤គឺ :

**១-មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺសុរានឹងមេរ័យ។

**២. ធាតុកម្មតាចិត្តំ** ចិត្តបំរុងនឹងផឹក ។

**៣. តជ្ជោវាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

**៤. តស្សធានំ**បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ។

បុ. បើមិនប្រកបព្រមដោយអង្គទាំង៤នេះ តើត្រូវទោសដែរឬទេ ?

វិ. បើមិនប្រកបព្រមដោយអង្គទាំង៤នេះទេ មិនត្រូវទោសក្នុងសុរាមេរ័យនោះឡើយ ។

បុ. សុរានឹងមេរ័យនោះដូចគ្នាឬផ្សេងគ្នា ?

វិ. មិនដូចគ្នាទេ ផ្សេងពីគ្នា សុរានោះគឺធ្វើដោយវត្ថុមានមេ្សៅជាដើម ; មេរ័យនោះគឺយកវត្ថុមានឈើជាដើមមកត្រាំងធ្វើឱ្យជូរជាដើម ។

បុ. សុរាមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? មេរ័យមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ ?

វិ. សុរាមាន ៥ យ៉ាងគឺ :

**១. បិដ្ឋសុរា** សុរាធ្វើដោយមេ្សៅ

**២.បូវសុរា** សុរាធ្វើដោយនំ

**៣.ឱទនសុរា** សុរាធ្វើដោយបាយ

**៤.កិណ្ណបក្ខិត្តា** សុរាដែលគេដាក់ពូជសុរា

**៥.សម្ភារសំយុត្តា** សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ មានគ្រាប់ម្រេចនឹងគ្រាប់ស្ពៃជាដើម ។

មេរ័យមាន៥ យ៉ាងគឺ :

**១.បុប្ផាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ

**២.ផលាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ

**៣.មធ្វាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍ឬដោយទឹកឃ្មុំ

**៤.គុឡាសវោ** ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ

**៥.សម្ភារសំយុត្តោ** ទឹកត្រាំដែលប្រកបព្រមដោយគ្រឿងផ្សេងៗមានផ្លែកន្ទួតព្រៃជាដើម ។

បុ. ចុះទឹកនោះកំណត់ប៉ុន្មាន ទើបឈ្មោះថាដាច់សីល ?

វិ. ទឹកនោះមិនកំណត់ទេដោយហោចទៅសូម្បីតែទឹកប៉ុនចុងស្បូវឱ្យតែឈ្មោះថាទឹកឱ្យចូលទៅកន្លងបំពង់កហើយឥតមានរួចចាក

ទោសឡើយ ។

បុ. បើបុគ្គលណាមួយ បានផឹកនូវសុរានឹងមេរ័យហើយលុះដល់ស្លាប់ទៅ នឹងទទួលសោយរងនូវសេចក្តីទុក្ខវេទនា យ៉ាងដូចម្តេច ?

វិ. បើបុគ្គលណាមួយបានផឹកនូវសុរានឹងមេរ័យហើយ ស្លាប់ទៅទៀងតែធ្លាក់ទៅសោយទុក្ខវេទនាក្នុងនរក ដោយអំណាចសេសសល់ផលកម្មអំពីនរកមក បានកើតជាសត្វតិរច្ឆានក្តី ជាមនុស្សក្តី តែកើតឡើងកាលណាហើយក៏ឆ្កួតវង្វេងបាត់ស្មារតី ៥០០ ជាតិឃ្លាតចាកមគ្គផលកុសលសីលទាន មិនមាននៅក្នុងសន្តានចិត្ត បើបុគ្គលណាវៀរមិនផឹកនូវសុរា នឹងមេរ័យនេះបាន អ្នកនោះកើតឡើងជាតិណាៗមានប្រាជ្ញាស្មារតីបរិបូណ៌ មិនចេះខ្វះខាត ហើយបានជាអ្នកប្រាជ្ញាអាចនឹងដឹកនាំអ្នកដទៃឱ្យធ្វើនូវអំពើកុសលផ្សេងៗ ។

បុ. វិកាលភោជនសិក្ខាបទនេះ ប្រែថាដូចម្តេច ?

វិ. វិកាលភោជនសិក្ខាបទនេះ ប្រែថា វៀរចាកនូវកិរិយាបរិភោគភោជនាហារក្នុងកាលខុស ។

បុ. វិកាល[1] ភោជនសិក្ខាបទនោះតើមានអង្គប៉ុន្មាន ? គឺអ្វីខ្លះ?

វិ. វិកាលភោជនសិក្ខាបទនោះមានអង្គ៣គឺ:

**១_វិកាលោ** កាលខុស

**២_យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាលគឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់

**៣_អជ្ឈោ ហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

បុ. បើមិនប្រកបដោយអង្គទាំង៣នេះ តើដាច់វិកាលភោជនសិក្ខាបទ ដែរឬទេ ?

វិ. បើមិនប្រកបព្រមដោយអង្គទាំ៣នេះទេ មិនដាច់វិកាលភោជនសិក្ខាបទឡើយ ។

បុ. ឯនចូតឹតសិក្ខាបទនោះ តើប្រែថា ដូចម្តេច ?

---

(១).ក្នុងគម្ពីរបង្ខាវិករណី មានអង្គ៣គឺ វិកាលតា១, យាវកាលិតា ១, អជ្ឈោហរណំ ១, ក្នុងខុទ្ទកបាឋវណ្ណនាមានអង្គ៤គឺវិកាលលោកាលខុស១, យាវកាលិកំ វត្ថុជាយាវកាលិក១,អជ្ឈោហរណំបានលេបចូលទៅក្នុងបំពង់១ក, អនុចិត្តកតា ភាពមិនឆ្កួត១ ។

វិ. ប្រែថា វៀរចាកនូវកិរិយារាំនិងកិរិយាច្រៀង នឹងប្រដាប់តាក់តែងរាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបផ្សេងៗ ឬដើរទៅមើលគេលេង នូវល្បែងផ្សេងៗមានរាំច្រៀងនិងប្រគំជាដើម ។

បុ. នច្ចគីតសិក្ខាបទ តើមានអង្គប៉ុន្មាន ?

វិ. មានអង្គ ៦ គឺ :

**១.នច្ចគីតានិ** ល្បែងមានរាំនិងច្រៀងជាដើម

**២.កត្តុកាមតាចិត្តំ** ចិត្តបំរុងនឹងធ្វើ

**៣.សុតទស្សនត្ថាយ គមនំ** ទៅដើម្បីស្ដាប់ ឬ មើល

**៤.មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម

**៥.ធារណាទិឆន្ទតា** សេចក្ដីប្រាថ្នានឹងប្រដាប់តាក់តែង

**៦.តស្សធារណំ** បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់សាយមានផ្កាកម្រងជាដើមនោះ ។

បុ. បើមិនប្រកបព្រមដោយអង្គទាំង៦នេះទេ តើត្រូវទោសក្នុងនច្ចគីតសិក្ខាបទដែរឬ ?

វិ. បើមិនប្រកបព្រមដោយអង្គទាំង៦នេះទេ មិនត្រូវទោសក្នុង

នច្ចគីតសិក្ខាបទឡើយ ។

បុ. ចុះបើដើរទៅស្រាប់តែជួបនឹងគេរាំមតែម្ដងឈ្មោះថាប្រព្រឹត្តកន្លងសិក្ខាបទនោះដែរឬទេ ?

វិ. មិនឈ្មោះថាប្រព្រឹត្តកន្លងទេ គ្រាន់តែសៅហ្មង លុះត្រាតែដើរទៅប៉ងនឹងមើលទើបឈ្មោះថាប្រព្រឹត្តកន្លង ។

បុ. ចុះដើរទៅប៉ងនឹងស្ដាប់ចម្រៀងមែនៗ ប៉ុន្តែចំរៀងនោះនាំឱ្យកើតនិព្វិទា នឿយណាយចាកកិលេសទាំងឡាយមានរាគៈជាដើម តើគួរឬមិនគួរ ? ព្រោះហេតុអ្វី ?

វិ. គួរ ព្រោះថាចំរៀងណាប្រកបដោយធម៌គួរមិនជាអ្វីទេ ដូចជាចំរៀងនាងកុម្ភទាសី ឬនាងនាគមាណវិកាជាដើម ។

បុ. អ្នកស្រុកអ្នកនគរគេតែងរាប់អានណាស់ក្នុងការរាំនឹងច្រៀង ចុះហេតុអ្វីបានជាព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គទ្រង់ហាមឃាត់ក្នុងការរាំនិងច្រៀងនោះជាដាច់ខាត ?

វិ. ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដែលបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គទ្រង់មានបំណងមិនចង់ឱ្យសត្វលោករីករាយសប្បាយ

ក្នុងកាមគុណទាំង៥នោះឡើយ ទ្រង់ក៏ចាត់បង់នូវអាសវធម៌មិនឱ្យ ផិតផាមក្នុងសន្តានចិត្តសព្វសត្វ ព្រោះទ្រង់យល់ថា ជាហេតុនឹងនាំសត្វឱ្យលិចលង់ក្នុងសង្សារនឹងធ្វើដំណើរសត្វឱ្យយឺតយូរដូច្នេះ បានជាទ្រង់ហាមឃាត់ក្នុងការរាំច្រៀងជាដើមនោះប្រយោជន៍ដើម្បីនឹងធ្វើដំណើរសត្វឱ្យកាន់តែឃ្លាតចាករូបសំឡេង-ក្លិន-រស-សម្ផស្ស-បន្តិចម្តងៗនឹងបានធ្វើជាតិកំណើតរបស់សត្វឱ្យខ្លីទៅៗជាលំដាប់ ។

បុ. ទោសរបស់ចំរៀងមានប៉ុន្មាន ?. គឺអ្វីខ្លះ ?

វិ. មាន៥យ៉ាងគឺ :

**១-អត្តនោបិ តស្មឹ សរេ សារជ្ជតិ** អ្នកច្រៀងរមែងត្រេកអរក្នុងសំឡេងរបស់ខ្លួនៗនោះ

**២-បរេបិ តស្មឹ សរេ សារជ្ជន្តិ** ជនទាំងឡាយដទៃរមែងត្រេកអរក្នុងសំឡេងនោះ

**៣-គហបតិបិ ឧជ្ឈាយន្តិ** គហបតីទាំងឡាយតែងពោលទោស

**៤-សរកុត្តិបិ និកាមយមានស្ស សមាធិស្សភង្គោ ហោតិ** បុគ្គលដែលពេញចិត្តនិងការស្លូត្រលោក់រលែកសំឡេងរមែងខូចសមាធិ

**៥-បច្ចិមាជនតា ធិដ្ឋានគតិមាបជ្ជតិ** ពួកជនខាងក្រោយ ដល់នូវទិដ្ឋានុគតិ(យកតម្រាប់តាម) ។ ត្រង់យល់ឃើញទោសរបស់ការ ច្រៀងប៉ុណ្ណោះបានជាទ្រង់ហាមឃាត់អំពើរនុ៎ះមិនឱ្យមាន ។

បុ. ព្រះសម្មាសម្ពុទ្ធទ្រង់ហាមឃាត់ មិនឱ្យរាំនឹងច្រៀងចំពោះ ខ្លួនឯងតែប៉ុណ្ណោះទេឬ ? ឬមួយក៏ទ្រង់អនុញ្ញាតឱ្យដើរមើលល្បែងនឹង ស្តាប់ចំរៀងផងបានដែរ ?

វិ. មិនមែនដូច្នោះទេ គឺព្រះអង្គទ្រង់ហាមឃាត់ចំពោះខ្លួនឯង ផងចំពោះដើរមើលរាំ នឹងស្តាប់ចំរៀង នឹងស្តាប់តូរ្យតន្ត្រីផ្សេងៗក្នុង លោកគឺថារាំច្រៀងដោយខ្លួនឯងក៏មិនបានទៅមើលឬស្តាប់គេក៏មិន បានជាដាច់ខាត ។

បុ. ចុះសីលទចូគីតនិងសីលមាលាផ្សេងៗគ្នាដូចម្តេចខ្លះ ?

វិ. ផ្សេងគ្នាគឺ ឯសីលទចូគីតនោះ ហាមមិនឱ្យរាំនឹងច្រៀងនឹង ប្រគំនឹងមើលនូវល្បែងផ្សេងៗ ឯសីលមាលានោះហាមមិនឱ្យទ្រទ្រង់ ប្រដាប់តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រងនឹងគ្រឿងក្រអូប នឹងគ្រឿងលាបផ្សេងៗមានទឹកអប់នឹងម្សៅជាដើម ។

 បុ. ឧច្ចាសយនសិក្ខាបទនេះ ប្រែថាដូចម្ដេច ?

វិ. ឯឧច្ចាសយនសិក្ខាបទនេះ ប្រែថា វៀរចាកនូវទីដេកនឹងទីអង្គុយ ដ៏ខ្ពស់ហួសប្រមាណ នឹងទីដេកទីអង្គុយដ៏ប្រសើរ ។

បុ. ទីដេកទីអង្គុយដូចម្ដេចដែលហៅថា ខ្ពស់ហួសប្រមាណទាំងដ៏ប្រសើរ ?

វិ. ទីដេកទីអង្គុយដ៏ខ្ពស់ហួសប្រមាណនោះគឺ :គ្រែឬតាំងដែលមានជើងខ្ពស់ជាង ៨ ធ្នាប់ព្រះសុគត, ទីដេកទីអង្គុយដ៏ប្រសើរនោះគឺកន្លែងដេកឬកន្លែងអង្គុយណាមួយ ដែលគេក្រាលដោយកម្រាល ដ៏វិចិត្រផ្សេងៗមានពូកញាត់ដោយសំឡីគរឬកប្បាស់កំពស់១ចំអាមឬ ១ហត្ថអង្គុយទ្រុកចុះក្រោកចោងឡើងជាដើម ហៅថាទីដេកទីអង្គុយដ៏ប្រសើរ ។

បុ. អាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងអាសនៈដ៏ប្រសើរនោះមានបុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. អាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងអាសនៈដ៏ប្រសើរនោះមាន ២០ យ៉ាងគឺ:

**១-អាសន្ទិ** អាសនៈដែលខ្ពស់ហួសប្រមាណ

**២-បល្លង្កៈ** គ្រែដែលមានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ

**៣-គោណកៈ** ព្រំដែលមានរោមវែងជាង៤ធ្នាប់

**៤-ចិត្តកៈ** កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វសាហាវ

**៥-បដិកៈ** កម្រាលមានពណ៌សដែលធ្វើដោយរោមសត្វ

**៦-បដលិក.** កម្រាលធ្វើដោយរោមសត្វជាផ្កាចង្កោម

**៧-តូលិកៈ** កម្រាលដែលញាត់ដោយសំឡីឬគរ

**៨-វិកតិកៈ** កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរោមសត្វមានសីហនឹងខ្លាធំជាដើម

**៩-ឧទ្ធលោមិ** កម្រាលដែលធ្វើដោយរោមសត្វមានរោមច្រាងតែម្ខាង

**១០-ឯកន្តលោមិ** កម្រាលដែលធ្វើដោយរោមសត្វមានរោមច្រាងឡើងទាំងពីរខាង

**១១-កដិស្សៈ** កម្រាលដែលធ្វើដោយខិនមាសនិងសូត្រហើយ

ចាក់ស្រែះដោយរតនវត្ថុ

**១២-កោសេយ្យៈ** កម្រាលធ្វើដោយសរសៃសូត្រហើយចាក់ដោយរតនវត្ថុ

**១៣-កុត្តកៈ** កម្រាលដែលធ្វើដោយរោមសត្វល្មមពូកស្រីរបាំ ១៦ នាក់ឈររាំបាន

**១៤-ហត្ថត្ថរៈ** កម្រាលសម្រាប់ក្រាលលើខ្នងដំរី

**១៥-អស្សត្ថរៈ** កម្រាលសម្រាប់ក្រាលលើខ្នងសេះ

**១៦-រថត្ថរៈ** កម្រាលសម្រាប់ក្រាលលើរថ

**១៧-អជិនប្បវេណី** កម្រាលដែលគេធ្វើដោយស្បែកខ្លាឃ្មុំ

**១៨-កទលិមិគបវរបច្ចត្ថរណៈ** កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វខ្លាឃ្មុំ

**១៩-សឧត្តរច្ឆទនៈ** ទីដេកដែលមានពិតានក្រហមពីខាងលើ

**២០-ឧភតោលោហិតកូបធានំ** កម្រាលដែលមានខ្នើយមានពណ៌ក្រហមទាំងពីរខាងគឺខ្នើយក្បាលនិងខ្នើយជើង ។

បុ. អាសនៈទាំង២០យ៉ាងនេះ សុទ្ធតែហាមមិនឱ្យដេកនឹង

អង្គុយទាំងអស់ ឬ ក៏មានអនុញ្ញាតឱ្យអង្គុយឬដេកបានខ្លះដែរ ?

វិ. អាសនៈទាំង ២០ យ៉ាងនេះលើកលែងតែអាសន្ទិ១,បល្លង្កៈ១ និងតូលិកៈ១ក្រៅពីនោះទ្រង់អនុញ្ញាតឱ្យអង្គុយបាន តែដេកមិនបានទេ, ឯអាសនៈទាំង ៣ នោះ ដេកក៏មិនបានអង្គុយក៏មិនបាន ។

បុ. ឧច្ចាសនៈ សិក្ខាបទនេះមានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ?

វិ. ឧច្ចាសនៈ សិក្ខាបទ មានអង្គ ៣ គឺ :

**១.ឧច្ចាសយនមហាសយនំ** ទីដេកអង្គុយដ៏ខ្ពស់ហួសប្រមាណ នឹងទីដ៏ប្រសើរ

**២.បរិភោគចិត្តំ** ចិត្តគិតនឹងដេកឬអង្គុយ

**៣.បរិភោគករណំ** បានដេកឬអង្គុយ ។

បុ. បើមិនប្រកបព្រមដោយអង្គទាំង ៣ នេះទេ តើត្រូវទោស ក្នុងសិក្ខាបទឧច្ចាសយនៈដែរឬទេ ?

វិ. មិនត្រូវទោសក្នុងឧច្ចាសយនសិក្ខាបទនេះទេ ។

បុ. ឧបោសថដែលបុគ្គលបានរក្សាតែ ១ ថ្ងៃទេ ហើយអាចបាច ផលប្រយោជន៍ឱ្យបានច្រើននោះ តើព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែង

ប្រារព្ធចំពោះ បុគ្គលណា ? បុគ្គលនោះឈ្មោះអ្វី ? ចូរអធិប្បាយរៀប រាប់តាមដំណើររហើយសំដែងរឿងរ៉ាវជាឧទាហរណ៍ខ្លះមកមើល ?

រ៉ៃ. ព្រះអង្គទ្រង់សំដែងចំពោះមហាឧបាសិកាឈ្មោះនាងវិសាខា។

អធិប្បាយថា បុគ្គលបានរក្សាឧបោសថសីលហើយរមែងបាន ផលានិសង្សច្រើនរកអ្វីប្រៀបផ្ទឹមមិនបាន សមដូចសេចក្តីដំណាលក្នុង ឧបោសថសូត្រថាៈ បុគ្គលបានរក្សាឧបោសថអស់យប់ ១ ថ្ងៃ ១ មក ចែកចេញជាចំណែក ១៦១ ហើយលើកចំណែក ១៥ ទុក យកតែ ចំណែក១មកចែកជា ១៦ ទៀត ហើយលើកចំណែក ១៥ ទុកយក ចំណែក១ ដែលតិចបំផុតទុកនឹងយកសម្បត្តិស្តេចចក្រពត្រាធិរាជទាំង ១៦នគរ មានដែនឈ្មោះអង្គៈនឹងដែនឈ្មោះមគធៈ ជាដើម មកប្រៀប ផ្ទឹមនឹងផលានិសង្ស ឧបោសថសីលក៏គង់មិនបានស្មើផលនៃឧបោសថ សីលដែលបុគ្គលបានរក្សាគ្រាន់តែ ១ចំណែកយ៉ាងតូចបំផុតផងឡើយ។ ដោយហោចទៅសូម្បីរក្សាបានតែត្រឹមកន្លះថ្ងៃប៉ុណ្ណោះ ដែលហៅថា អឌ្ឍុបោសថ គឺឧបោសថពាក់កណ្តាលនេះ ក៏គង់ព្រះសម្មាសម្ពុទ្ធជា ម្ចាស់ព្រះអង្គទ្រង់សរសើរថា មានផលច្រើនជាអនេកទៅហើយ

ចំណែកបើឧបោសថពេញលេញនឹងមានផលានិសង្សយ៉ាងណាទៅហ្ន៎ ។

សេចក្ដីដំណាលថា : ក្នុងកាលដែលកន្លងទៅហើយ ព្រះបរមពោធិសត្វទ្រង់បានសោយរាជ្យសម្បត្តិជាស្ដេចក្នុងពារាណសី ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាបាន បរិចាគទាននឹងរក្សានូវឧបោសថសីលដោយព្រះអង្គឯងជានិច្ចកាល ឥតមានធ្វេសប្រហែសឡើយ ។ ហើយក៏ទ្រង់ទូន្មានប្រៀនប្រដៅប្រជាជនដែលអាស្រ័យនៅក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គទាំងប៉ុន្មាន ឱ្យរក្សានូវឧបោសថគ្រប់ៗគ្នាផង, ចំណែកខាងបុរោហិម្នាក់ ដែលព្រះរាជាទ្រង់ព្រះរាជទានយសស័ក្តិ ដំណែងថានៈ ជាអាមាត្យធំចម្បងសម្រាប់កាត់ក្ដី មិនបានរក្សានូវឧបោសថនឹងគេសោះ ។ ថ្ងៃមួយក៏បានទៅគាល់ស្ដេច ជួនថ្ងៃនោះជាថ្ងៃឧបោសថផង ស្ដេចព្រមទាំងរាជអាមាត្យ ដែលមាននូវក្នុងព្រះបរមរាជវាំងទាំងប៉ុន្មាន ក៏នាំគ្នារក្សានូវឧបោសថទាំងអស់គ្នា ។

ចំណែកខាងបុរោហិត ឥតបានរក្សានឹងគេបន្តិចបន្តួចសោះក៏គិតថា "អញនឹងត្រឡប់មកដល់ផ្ទះវិញអញនឹងរក្សាឧបោសថពុំខាន"។ លុះដល់បុរោហិតនោះត្រឡប់មកផ្ទះវិញ ក៏ខ្ញុំរមាត់ដុះធ្មេញស្អាតបាត

ហើយក៏តាំងចិត្តថា: "អញនឹងរក្សាឧបោសថក្នុងវេលាល្ងាចនេះ អញមិនបរិភោគអាហារសោះឡើយ" ។ ឧបោសថនោះលោកហៅថា ឧបឌ្ឍុបោសថ គឺឧបោសថពាក់កណ្តាលថ្ងៃ ;លុះគាត់ធ្វើមរណកាលទៅក៏បានទៅកើតជាវិមានិកប្រេតសោយទិព្វសម្បត្តិ ស្ថិតនៅក្នុងវិមានជាវិការៈនៃមាសក្នុងសួនស្វាយប្រមាណ៣យោជន៍ មានស្រីទេពកញ្ញា ១ ហ្មឺន ៦ ពាន់ជាបរិវារ ។ នេះដោយផលនៃឧបឌ្ឍុបោសថ ដែលខ្លួនបានរក្សាពាក់កណ្តាលថ្ងៃប៉ុណ្ណោះឯង ។

សូមសំដែងរឿង ១ ទៀត សេចក្តីដំណាលថា : ក្នុងកាលដែលកន្លងទៅហើយ មានសេដ្ឋីម្នាក់នៅក្រុងពារាណសីឈ្មោះសុចិបរារៈជាអ្នកមានទ្រព្យសម្បត្តិ ៨០ កោដិ ជាបុគ្គលត្រេកអររីករាយក្នុងបុណ្យកុសល មានទាននឹងសីលជាដើម ។ តែងទូន្មាននឹងប្រៀនប្រដៅកូនប្រពន្ធនឹងជនដែលអាស្រ័យនៅជាមួយទាំងប៉ុន្មាន ដោយហោចទៅសូម្បីតែកូនក្មេងតូចៗដែលទើបនឹងកើត១ថ្ងៃក៏គាត់ឱ្យរក្សានូវឧបោសថទាំងអស់ ។ គ្រានោះ មានបុរសកំសត់ម្នាក់ ជាអ្នកទីទាល់ក្រឥតទីពឹងជាអ្នកមានជីវភាពដោយសារតែស៊ីឈ្នួលគេប៉ណ្ណោះ ។ ថ្ងៃមួយ បុរស

នោះក៏ចូលទៅកាន់សំណាក់សេដ្ឋី ដើម្បីនឹងធ្វើនូវកម្មករ. សេដ្ឋីសួរថា: "អ្នកមករកអ្វី" ? ; បុរស់នោះក៏ជំរាប់ថា: "បពិត្រលោកសេដ្ឋី ខ្ញុំបាទមកសុំសំណាក់នៅអាស្រ័យនឹងលោកដើម្បីធ្វើជីវភាពជាកម្មករក្នុងសំណាក់លោក" ។ សេដ្ឋីនិយាយប្រាប់បុរស់នោះថា: "ខ្ញុំទទួលជួយទំនុលបំរុងអ្នកបាន" ។ បុរស់នោះក៏ចាប់ធ្វើការតាំងពីពេលនោះមកយកចិត្តទុកដាក់ ឥតមានធ្វេសប្រហែសក្នុងការងារឡើយជាបុគ្គលទូន្មានបានដោយងាយ សេដ្ឋីក៏មានសេចក្តីបេញចិត្តនឹងបុរស់នោះណាស់ ។ លុះដល់ថ្ងៃឧបោសថ សេដ្ឋីក៏បង្គាប់នាងទាសីឱ្យចាត់ចែងចំអិនអាហារតាំងពីព្រលឹមរួចហើយ ក៏នាំគ្នាសមាទានឧបោសថសីលគ្រប់គ្នាទាំងស់ ។ ឯបុរសកំសត់នោះទៅធ្វើការតាំងពីព្រលឹមទល់ព្រលប់ទើបប្រឡប់មកដល់ផ្ទះវិញ សេដ្ឋីប្រាប់នាងទាសីឱ្យរៀបចំអាហារដើម្បីឱ្យបុរសនោះបរិភោគ ។ បុរសនោះកាលបើបានឃើញដូច្នោះ ក៏នឹកសង្ស័យក្នុងចិត្តហើយសួរទៅនាងទាសីថា: "នែនាងក្នុងថ្ងៃមុនៗ មនុស្សទាំងឡាយក្នុងផ្ទះនេះតែងនិយាយគ្នាអ្វីអែក្នុងពេលបរិភោគអាហារម្តងៗចំឡែកតែល្ងាចនេះ សំឡេងអ្នកទាំងនោះក៏ស្ងាត់

ឈឺងមិនឮសូរនិយាយអ្វីបន្តិចបន្តួចសោះ" ? នាងទាសីនិយាយរ៉ាយ
រ៉ាប់ប្រាប់ទៅបុរសនោះថា "ថ្ងៃនេះជាថ្ងៃឧបោសថ ជនទាំងអស់គ្នា
ក្នុងផ្ទះនេះសុទ្ធតែរក្សាឧបោសថ គេមិនត្រូវការបរិភោគអាហារពេល
ល្ងាចទេ សូមអ្នកបរិភោគតែម្នាក់ឯងចុះ" ។ បុរសកំសត់សួរទៅ
ទៀតថាៈ "ចុះជនទាំងអស់គ្នានោះជាអ្នករក្សាឧបោសថឬ ? នាងទាសី
ប្រាប់ថាៈ គេសុទ្ធតែរក្សានូវឧបោសថទាំងអស់" ។

បុរសនោះថាៈ"ខ្ញុំមិនបានសមាទានរក្សាឧបោសថតាំងពីព្រលឹម
មកទេ ប្រសិនជាសមាទានសីលពីត្រឹមពេលនេះទៅបានដែរឬទេ ? ;
នាងទាសីប្រាប់ថាៈ "អ្នករក្សាបានឥតមានទាស់អ្វីទេ" ។ ឯបុរស
កំសត់ក៏សមាទានរក្សានូវឧបោសថតាំងពីពេលនោះតទៅ ។ ឧបោសថ
នោះឈ្មោះថា ឧបឌ្ឍុបោសថគឺឧបោសថពាក់កណ្តាល ។

បុរសនោះតាំងពីបានសមាទានវេលាណា ខំសង្រួមកាយវាចា
ចិត្តឱ្យស្អាតបរិសុទ្ធមិនឱ្យសៅហ្មងសិក្ខាបទណាមួយឡើយ ។ លុះពាក់
កណ្តាលរាត្រីខ្យល់បណ្តាលកើតឡើងក្នុងពោះជាខ្លាំងដោយអំណាចខ្លួន
អត់អាហារតាំងពីព្រឹមទល់ព្រលប់មិនបានបរិភោគអាហារសោះ ក៏ផ្តាច់

បង់ជីវិតន្ទ្រីយ៍ស្លាប់ភ្លាមក្នុងខណៈនោះទៅ ។ ដោយអំណាចអានិសង្ស នៃឧបោសថដែលខ្លួនបានរក្សាហើយ ក៏ប្រោនវិញ្ញាណខន្ធឱ្យទៅកើតជាព្រះរាជបុត្រព្រះបាទពារាណសី ព្រះនាមឱទយកុមារប្រកបដោយជាតិស្សរញ្ញាណរឭកជាតិកំណើតខ្លួនបាន ។ លុះព្រះវរបិតាទិវង្គតទៅក៏បានសោយរាជ្យជាស្តេចធំមួយព្រះអង្គ ទ្រង់ព្រះនាមឧទយរាជ ដោយផលនៃឧបោសថប៉ុណ្ណោះឯង ។

គ្រាន់តែរក្សាឧបោសថពាក់កណ្តាលថ្ងៃប៉ុណ្ណោះ មិនបានពេញ ១ថ្ងៃ១យប់ផងក៏គង់ព្រះសហ្សសម្តុទ្ធទ្រង់សំដែងសរសើរថា: អស្ចារ្យម្ល៉ោះទៅហើយ ចំណង់បើសប្បុរសទាំងឡាយ បានរក្សាឧបោសថរាល់៧ខែ មិនដាច់នឹងរាប់ផលានិសង្សថា ប៉ុណ្ណេះប៉ុណ្ណោះឯណាបាន នឹងមានផលានិសង្សរឹងរឹតតែវិសេសក្រៃលែងជាងនេះទៅទៀត ។

ដូច្នេះសប្បុរសទាំងឡាយគប្បីរំពឹងគិតពិចារណាមើលទៅចុះ គួរណាស់តែខំប្រឹងរកឧបាយលៃលកឿតរក្សា បាដិហារិយឧបោសថថែមទៀត បើមិនបានច្រើនក្នុងមួយ ១ ឆ្នាំឱ្យបាន១ បក្ខ ឬ ២ បក្ខក៏ជាការគួរប្រពៃណាស់ទៅហើយ ព្រោះថា អដ្ឋង្គិកឧបោសថ គឺឧបោសថ

ដែលប្រកបដោយអង្គទាំង៨នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងប្រារព្ធចំពោះនឹងមហាឧបាសិការណ្ឌោះនាងវិសាខារួចហើយ ។

សូមសំដែងរឿងមួយទៀត សេចក្តីដំណាលថាៈក្នុងកាលកន្លងទៅហើយព្រះបរមពោធិសត្វទ្រង់ព្រះនាមសាធិនទ្រង់បានសោយរាជសម្បត្តិក្នុងនគរមិថិលា ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាសាងសាលាឆទាន ហើយក៏ទ្រង់លះបង់ព្រះរាជទ្រព្យ ផ្ទាល់ព្រះអង្គ៦សែនកហាបណៈតែរាល់ថ្ងៃ ទ្រង់រក្សាសីល៥ផងឧបោសថសីលផងរាល់ៗថ្ងៃឧបោសថមិនដែលខាន ។

ចំណែកខាងប្រជាជន ដែលអាស្រ័យនៅក្នុងដែនទាំងប៉ុន្មានក៏ឋិតនៅក្នុងឱវាទរបស់ព្រះអង្គគ្រប់ៗគ្នា ហើយបាននាំគ្នាធ្វើបុណ្យឱ្យទាន, លុះជនទាំងនោះស្លាប់ទៅ ក៏បានទៅកើតជាទេវតាទាំងអស់គ្នាគ្មានសល់ម្នាក់ឡើយ ។

បណ្តាទេវតាទាំងនោះ តែងទៅប្រជុំក្នុងសាលាសុធម្មសភាហើយតែងពោលសរសើរ អំពីគុណទាំងឡាយមានសីលគុណជាដើមរបស់ព្រះរាជារាល់ៗថ្ងៃ '។ ឯទេវតាទាំងឡាយដ៏សេស បានស្តាប់នូវ

គុណសម្បត្តិរបស់ព្រះរាជាដូច្នោះ ក៏មានចិត្តជ្រះថ្លាប្រាថ្នាចង់ឃើញ ចង់ស្គាល់ព្រះរាជា មិនដឹងជាគិតរកឧបាយយ៉ាងណា ក៏ស្រាប់តែសក្កទេវរាជជ្រាបច្បាស់នូវចិត្តរបស់ទេវតាទាំងឡាយនោះ ហើយក៏បង្គាប់ប្រើមាតុលីទេវបុត្តថា "នៃមាតុលី, ចូរអ្នកទៅអញ្ជើញព្រះបរមពោធិសត្វឱ្យមកគង់លើរថរបស់យើងហើយនាំចូលមកកាន់ទេវនគរ"។

មាតុលីទេវបុត្រក៏បរវេជ្ជយន្តរថ ទៅកាន់នគរមិថិលា ហើយអញ្ជើញព្រះបរមពោធិសត្វ ឱ្យព្រះអង្គឡើងគង់លើរថយន្ត ហើយបរទៅកាន់ទេវនគរទៅ ; ទេវតាទាំងឡាយបានឃើញព្រះពោធិសត្វហើយក៏មានចិត្តជ្រះថ្លា ក្រោកឡើងទទួលដោយគួរសម ។

ចំណែកសក្កទេវរាជ បានបែងចែកនូវនគរទេវតាផង នូវស្រីទេពអប្សរពីរកោដិកន្លះផង នូវវេជ្ជយន្តប្រាសាទពាក់កណ្ដាលៗផង ថ្វាយព្រះបរមពោធិសត្វ ព្រះអង្គក៏ទ្រង់បានសោយទិព្វសម្បត្តិក្នុងស្ថានលោកនោះ ចំនួន៧០០ឆ្នាំមនុស្ស លុះព្រះបរមពោធិសត្វ ទ្រង់បានសោយទិព្វសម្បត្តិក្នុងស្ថានទេវតាហើយ ដល់អស់បុណ្យក៏ទ្រង់នឿយណាយក្នុងសម្បត្តិទិព្វ ។ ទើបសក្កទេវរាជ ទ្រង់ជ្រាបច្បាស់ថា

ព្រះបរមពោធិសត្វអស់បុណ្យហើយ  ក៏ទ្រង់ប្រើមាតលិទេវបុត្រឱ្យបរ វេជ្ជយន្តរថជូនត្រឡប់មកកាន់នគរមិថិលាវិញ.ឯមាតលិទេវបុត្រនាំព្រះ បរមពោធិសត្វ  មកដាក់ព្រះអង្គឱ្យចុះ  ត្រង់សួនច្បារ  បុរសអ្នករក្សា សួនច្បារ  បានឃើញព្រះអង្គហើយ  ក៏ទៅក្រាបបង្គំទូលព្រះរាជាទ្រង់ ព្រះនាមនារទៈដើម្បីថ្វាយដំណឹងឱ្យព្រះអង្គជ្រាប ។ សេចក្តីដំណាល ថា: ព្រះរាជាអង្គនោះត្រូវជាចៅព្រះបរម ពោធិសត្វ៧ដំណមកហើយ អាយុមនុស្សក្នុងសម័យជាន់នោះ៧០០ឆ្នាំ។

ចំណែកព្រះបរមពោធិសត្វ  ដែលមានព្រះជន្មាយុនៅទាំង អម្បាលនេះគឺនៅដោយអំណាចផលបុណ្យរបស់ព្រះអង្គទេតើ ? ព្រះ រាជាទ្រង់ព្រះនាមនារទៈ  បានយាងទៅថ្វាយបង្គំព្រះបរមពោធិសត្វ ហើយ ក៏លើករាជសម្បត្តិប្រទាន ប៉ុន្តែក្នុងពេលនោះ លោកមិនទទួល លោកក៏ក្រាបទូលត្រឡប់ទៅវិញថា សូមទ្រង់ព្រះមេត្តាប្រោស ទូល ព្រះបង្គំមកនេះឥតត្រូវការនឹងរាជសម្បត្តិទេ  គឺមកប្រាថ្នាដើម្បីធ្វើ បុណ្យម្យ៉ាងទេតើគឺថាខំសន្សំធ្វើបុណ្យកុសលមានការ ឱ្យទានជាដើម ប៉ុណ្ណោះ ។

ចំណែកព្រះរាជាទ្រង់ព្រះនាមនារទៈ ក៏មានព្រះទ័យត្រេកអរក្រៃពេក ហើយក៏ជួយចាត់ចែងក្នុងកិច្ចធ្វើទាននោះយ៉ាងធំ ឯព្រះបរមពោធិសត្វក៏ខំប្រឹងធ្វើនូវមហាទានអស់គំរប់៧ថ្ងៃ ហើយទ្រង់ទិវង្គតទៅបានទៅកើតក្នុងស្ថានតាវតឹង្សដដែលវិញ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងព្រះសទ្ធម្មទេសនាចំពោះឧបាសក-សិកាទាំងឡាយដែលបានរក្សាឧបោសថថា "សប្បុរសទាំងឡាយឧបោសថកម្ម គួរអ្នកទាំងឡាយរក្សាឱ្យស្អាតបរិសុទ្ធកុំឱ្យសៅហ្មងព្រោះថាអ្នកប្រាជ្ញទាំងឡាយក្នុងបុរាណកាល លោកតែងបានទៅកើតក្នុងទេវលោកទាំងបច្ចុប្បន្នសរីរៈក៏សឹងមាន ដោយអំណាចឧបោសថកម្មដែលខ្លួនបានរក្សាដោយយកចិត្តទុកដាក់ប៉ុណ្ណោះឯង ។

## សមាទាន

បុ.សមាទានមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. សមាទានមាន២ យ៉ាងគឺ: ឯកជ្ឈសមាទាន១, បច្ចេកសមាទាន១ ។

បុ. ដូចម្ដេចហៅថា ឯជ្ឈសមាទាន ? ចូរអធិប្បាយ

វិ. ដែលហៅថា ឯកជ្ឈសមាទានគឺៈ សមាទានចង់ចេតនា ឬថា រួបរួមចេតនាជាមួយគ្នា ។

អធិប្បាយថាៈ សមាទានរួបរួមបទខាងចុងតែម្តងមិនបាច់សមាទានពីសិក្ខាបទដើម ដរាបដល់ចប់ គ្រាន់តែសមាទានថា ឥមានិ {បញ្ច / អដ្ឋ} សិក្ខាបទានិដូច្នេះ ជាការស្រេច ។ ប៉ុន្តែការសមាទាននោះ មិនមែនថាខ្លួនឯងទេ គឺថាតាមលោកអ្នក-អ្នកឱ្យ ៣ ផងសមាទានយ៉ាងនេះហៅថា ឯជ្ឈសមាទាន ។

បុ. ចុះបុគ្គលរក្សាជាឯកជ្ឈសមាទានដូច្នេះហើយ បើសិក្ខាបទណាមួយដាច់ តើសិក្ខាបទដទៃដាច់ដែរឬទេ ? ព្រោះហេតុអ្វី ? មានទោសឬទេ ?

វិ. សិក្ខាបទណាមួយដាច់ហើយសិក្ខាបទដទៃដាច់ជាប្រាកដ, ព្រោះសមាទានចង់វិរតិចេតនា រួបរួមសិក្ខាបទជាមួយគ្នា ។ មានទោសតាមចំណែករៀង១ខ្លួន គឺថាបើដាច់សីលណាត្រូវមានទោសតែត្រង់សីលនោះប៉ុណ្ណោះ ឯសីលដែលសល់នៅទាំងប៉ុន្មានមិនមានទោសអ្វីឡើយ ។

បុ. ដូម្តេច ដែលហៅថាបច្ចេកសមាទាន ?

វិ. បច្ចេកសទាន គឺសមាទានមិនបានចង់ចេតនារួមសិក្ខាបទជាមួយគ្នាឡើយ គឺសមាទានញែកសិក្ខាបទចេញដាច់ដោយឡែក ។ ផ្សេងៗពីគ្នា គឺថាបើលោកឱ្យសីល ៥ ៨ ក្តីត្រូវឱ្យទទួលថាតាមលោកតាំងពីសិក្ខាបទដើម ដរាបដល់សិក្ខាបទខាងចុងសមាទានយ៉ាងនេះហៅថា បច្ចេកសមាទា ។

បុ. ចុះបុគ្គលសមាទានសីល ជាបច្ចេកសមាទានហើយ ធ្វើឱ្យដាច់សិក្ខាបទណាមួយ សិក្ខាបទដទៃដាច់ដែរឬទេ ? ព្រោះហេតុអ្វី ? មានអានិសង្សទេ ? មានទោសដូចម្តេច ?

វិ. មិនដាច់ទេ គឺសិក្ខាបទដ៏ទៃក្រៅពីនោះដែលសល់នៅទាំងប៉ុន្មាន មិនបានដាច់ផងឡើយ សល់នៅគង់ទ្រង់ពេញបរិបូណ៌ដដែល ព្រោះសមាទានសិក្ខាបទមួយៗ ហួរហែទៅគ្រប់សិក្ខាបទទាំងអស់ , ឯអានិសង្សបាន ; ឯចំណែកខាងទោសនោះសោតទៀត ក៏មានចំពោះតែសិក្ខាបទណាដែលខ្លួនធ្វើឱ្យដាច់ប៉ុណ្ណោះ ត្រង់សិក្ខាបទដែលនៅសល់ខាងទាំងប៉ុន្មាន ដែលខ្លួនមិនបានធ្វើឱ្យដាច់នោះ ក៏ឥតមាន

ទោសអ្វីឡើយ ។

បុ. ចុះសិក្ខាបទទាំង៨ សិក្ខាបទណាជាលោកវជ្ជៈ មានទោសក្នុងលោកជាធម្មតា ? សិក្ខាបទណាជាបណ្ណត្តិវជ្ជៈ មានទោសព្រោះបញ្ញត្តិ ?

វិ. សិក្ខាបទ ៥ ខាងដើម តាំងពីបាណាតិបាតរហូតដល់សុរា ជាទីបំផុតជាលោកវជ្ជសិក្ខាបទ មានទោសសម្រាប់លោកជាធម្មតា, បើទុកណាមិនបានសមាទានក្តី ឬថាបានសមាទានក្តី តែប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយហើយ ឬថាធ្វើឱ្យដាច់ធ្លុះធ្លាយគ្រប់សិក្ខាបទទាំង ៥ ក៏គង់មិនរួចអំពីទោសនោះៗឡើយត្រូវមានទោសដូចគ្នា ។ ព្រោះសិក្ខាបទទាំង៥នេះ ហៅថា និច្ចសីល ជាសីលធម្មតាមាននៅគ្រប់រូប។

សិក្ខាបទទាំង ៣ ដែលមាននៅខាងចុងគឺ វិកាលសិក្ខាបទ , នច្ចគីតសិក្ខាបទ, នឹងឧច្ចាសយនសិក្ខាបទ ជាបណ្ណត្តិវជ្ជៈ មានទោសព្រោះប្រព្រឹត្តកន្លងបញ្ញត្តិ បើសប្បុរសទាំងឡាយបានទទួលសមាទានហើយធ្វើឱ្យដាច់នូវសិក្ខាបទទាំង ៣ សិក្ខាបទណាមួយហើយ ឬ ថាធ្វើឱ្យដាច់ទាំង៣ នោះ ក៏គង់តែមិនមានទោសជាទម្ងន់ឡើយ ទោសគ្រាន់

តែឥតបានផលប៉ុណ្ណោះ ។

បុ. សិក្ខាបទទាំង៥ មានបាណាតិបាតជាដើម មានសុរាជាទីបំផុតបុគ្គលប្រព្រឹត្តកន្លងហើយ មានទោសធ្ងន់ស្រាលជាងគ្នា ឬដូចគ្នា ឬ ក៏ស្មើៗគ្នាតាំងអំពីបាណាតិបាតរហូតទៅ ?

វិ. ធ្ងន់ស្រាលប្រហែលគ្នា មិនកំណត់ថាជាសិក្ខាបទណាទេ ស្រេចតែប្រព្រឹត្តកន្លងដ៏ក្លាហានលើសិក្ខាបទណាជាងគេ អំពើអាក្រក់ក៏ឱ្យផលតាមសិក្ខាបទដែលខ្លួនប្រព្រឹត្តកន្លងនោះ ។

បុ. សីលបែកធ្លាយហើយ សរណគមន៍បែកធ្លាយដែរ ឬ ទេ ? ព្រោះហេតុអ្វី ?

វិ. សរណគមន៍ មិនបែកធ្លាយទេ ព្រោះថាមានសទ្ធាជាឫស គឺមានសទ្ធាជឿបុណ្យជឿបាបមិនទាន់អស់នៅឡើយ ទើបបានលោកពោលថាមិនបែកធ្លាយមិនវិនាស ឯសីលនោះគឺកើតឡើងដោយកម្លាំងចេតនា គឺគ្រាន់តែវិរតិចេតនាប៉ុណ្ណោះ ។

បុ. ចុះបើដាច់សរណគមន៍ហើយ តើសីលបែកធ្លាយដែរឬទេ ? ព្រោះហេតុអ្វី ?

វិ. សីលបែកធ្លាយ, ព្រោះសរណគមន៍ជាឫសគល់ បើអស់សទ្ធាហើយ សីលដូចម្តេចឡើយនឹងនៅផងបាន ។

បុ. ចុះពាក្យថា ឧបាសកឧបាសិកា(ប្រែថា) អ្នកចូលទៅជិតស្និតព្រះត្រៃសរណគមន៍ គឺជាអ្នកយកព្រះរតនត្រ័យជាទីពឹងទីរឭក មិនយកវត្ថុដទៃជាពឹងទីរឭកទេ ឈ្មោះថាមានសរណគមន៍ស្ថិតនៅក្នុងសន្តានហើយ រមែងជឿនូវវត្ថុទាំងឡាយដែលព្រះ ពុទ្ធជាបរមគ្រូទ្រង់បញ្ញត្តនឹងអនុញ្ញាតមកហើយសុទ្ធតែជាវត្ថុពិត១ ក៏ខំប្រព្រឹត្តតាម , ដូចជាវត្ថុពិតគឺសីលដែលខ្លួនប្រព្រឹត្តតាម ហើយត្រឡប់ធ្វើវត្ថុគឺសីលនោះឱ្យបែកធ្លាយទៅវិញ តើចាត់បុគ្គលនោះជាឧបាសកឧបាសិកាបានដែរឬ ? ចាត់ចូលក្នុងឧបាសកពួកណា ?

វិ. បានខ្លះដែរ ចាត់ចូលក្នុងឧបាសកពពួកគឺ :

**១-ចណ្ឌាលឧបាសក** ឧបាសកខូចកាច

**២-មលឧបាសក** ឧបាសកមានធម៌ជាមន្ទិល

**៣-បដិកិដ្ឋឧបាសក** ឧបាសកព្រះពុទ្ធទ្រង់តិះដៀល ។

បុ. សមាទានសីលម្នាក់ឯង នឹងគ្នាច្រើនវិសេសជាងគ្នាយ៉ាង

ដូចម្តេច ?

វិ. មិនវិសេសជាងគ្នាទេ គឺដូចគ្នា ស្រេចនឹងការទទួលហើយវៀរចាកគ្រប់សិក្ខាបទ ប្រតិបត្តិឱ្យត្រឹមត្រូវប៉ុណ្ណោះទេ មិនស្រេចនឹងការសមាទានទេ ។

បុ. សីលកើតអំពីអ្នកឱ្យឬអ្នកទទួល ?

វិ. កើតអំពីអ្នកទទួល មិនមែនកើតអំពីអ្នកឱ្យទេ ព្រោះសីលរបស់ គ្រហស្ថជាចេតនាកម្ម, ខុសអំពីសីលរបស់សាមណេរសីលរបស់សាមណេរជាបញ្ញត្តិកម្ម ។

បុ. អ្វីហៅថាសីល ?

វិ. ចេតនាហៅថាសីល ។

បុ. បុគ្គលមិនទាន់សមាទានរក្សាសិលទេ តើមានធម៌អ្វីខ្លះទៅដឹកនាំបុគ្គលនោះឱ្យសមាទានបាន ? បានសមាទានរក្សាសីលហើយតើមានធម៌អ្វីខ្លះជាគ្រឿងគាំពារទ្រទ្រង់ទុកមិនឱ្យបែកធ្លុះធ្លាយ ពព្រុះពពាលឬសៅហ្មងទៅវិញបាន ? ចូរអធិប្បាយដោយសង្ខេប

វិ. មានធម៌ពីរយ៉ាងជាគ្រឿងដឹកនាំ ជាគ្រឿងទ្រទ្រង់ទុក ឯធម៌

ពីរយ៉ាងនោះគឺ :

**១-ហិរិ** ធម្មជាតិដែលមានសេចក្តីអៀនខ្មាសនឹងអំពើទុច្ចរិត

**២-ឱត្តប្បៈ**ធម្មជាតិដែលមានសេចក្តីតក់ស្លុត រន្ធត់នឹងផលរបស់ទុច្ចរិត ។

អធិប្បាយថា : កាលបើធម៌ទាំងពីរយ៉ាងនេះកើតឡើយ ក្នុងសន្តានចិត្តនៃបុគលណាមួយហើយ បុគ្គលនោះបើទុកជាមិនទាន់បានរក្សាសីលក៏គង់តែរក្សាពុំខាន គឺខំប្រឹងប្រែងស្ទុះស្ទារក្សាឱ្យទាល់តែបានសំរេចបើបានរក្សារួចហើយ ក៏ជាការល្អប្រពៃណាស់បើទុកជាមានហេតុដល់ជីវិត ក៏សូ៊ប្រថុយមិនហ៊ានទំលាយបង់នូវសីលរបស់ខ្លួនដែរ។

ប. ធម៌ពីរយ៉ាងគឺ ហិរិនិងឱត្តប្បៈនេះ មានធម៌អ្វីជាំទាស់ប្រឆាំងរាំងរាជាសត្រូវមិនឱ្យឡើងបានដែរ ឬ ទេ ? ចូរអធិប្បាយដោយសង្ខេប

វ. មានធម៌ពីរយ៉ាងគឺ :

**១-អហិរិកំ** សភាពមិនអៀនខ្មាសនឹងអំពើទុច្ចរិត

**២-អនោត្តប្បំ** សភាពមិនក្តៅក្រហាយនឹងតក់ស្លុតរន្ធត់មិនខ្លាច

អំពើទុច្ចរិត ។

អធិប្បាយថា ធម៌ទាំងពីរយ៉ាងនេះ កាលបើកើតឡើងក្នុងសន្ដាន នៃបុគ្គលប្រុសស្រីណាមួយហើយ បុគ្គលនោះបើមិនទាន់បានរក្សាសីលនៅឡើយ ក៏នឹងរកឱកាសដើម្បីនឹងរក្សាសីលនោះពុំបានឡើយ បើបានរក្សារួចហើយសូម្បីតែហេតុបន្តិចបន្តួចក៏គង់តែធ្វើ ឱ្យដាច់ធ្លុះធ្លាយពព្រុះពពាលសៅហ្មងទៅវិញមិនខាន ។

ប្ុ. សីលចែកចេញជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

វិ. ចែកចេញជាពីរយ៉ាងគឺ :

**១-បញ្ចង្គិកសីល** សីលដែលប្រកបដោយអង្គ ៥ គឺមិនសម្លាប់សត្វ១, មិនផឹកនៅទឹកស្រវឹងរឹងគឺសុរានឹងមេរ័យ១ ;ទាំង៥ប្រការនេះហៅថាបញ្ចសីល ។

**២-អដ្ឋង្គិកសីល** សីលដែលប្រកបដោយអង្គទាំង៨ គឺមិនសម្លាប់, មិនលួចទ្រព្យគេ១, មិនសេពនូវមេថុនធម្ម១, មិននិយាយនូវពាក្យកុហក១, មិនមើលរាំច្រៀងប្រគំមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ មិនប្រដាប់តាក់តែងស្អិតស្អាតរាងកាយដោយផ្កាកម្រង

គ្រឿងក្រអូបនឹងគ្រឿងលាបផ្សេងៗ១, មិនដេកឬអង្គុយលើគ្រែនឹងតាំងដ៏ខ្ពស់ហួសប្រមាណ ដែលក្រាលដោយគ្រឿងកម្រាលជាអកុប្បិយ១ ; ហៅថាអដ្ឋង្គិកសីលរួមទាំងអស់ត្រូវជា៨យ៉ាង ។

បុ. បញ្ចង្គិកសីល ជាសីលដែលអ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើម លោកកំណត់ឱ្យឈ្មោះថា ដូចម្ដេចខ្លះ ?

វិ លោកកំណត់ឱ្យឈ្មោះថានិច្ចសីល ជាសីលគឺសប្បុរសទាំងឡាយគប្បីកាន់កាប់ថែរក្សាជានិច្ច មិនឱ្យដាច់រាល់ៗថ្ងៃ គ្រប់ខែនឹងឆ្នាំទាំងអស់ដរាបដល់អស់ជីវិត ។

បុ. សីលទាំង៥នេះ ហេតុអ្វីក៏លោកអ្នកប្រាជ្ញទាំងឡាយកំណត់ឱ្យឈ្មោះថា អរិទ្រព្យ ?

វិ. បានជាលោកឱ្យឈ្មោះថា អរិយទ្រព្យព្រោះជាទ្រព្យដ៏ប្រសើររបស់ព្រះអរិយបុគ្គល លោកតែងតែប្រព្រឹត្តរក្សាជាប់ជានិច្ច ។

បុ. ហេតុអ្វីក៏លោកឱ្យឈ្មោះថាគរុធម៌ ?

វិ. បានជាលោកឱ្យឈ្មោះថាគរុធម៌នោះ គឺជាធម៌មានទម្ងន់ គួរគោរពប្រណិប័តន៍ កោតក្រែងរបស់អ្នកប្រាជ្ញទាំងឡាយ ។

បុ. ហេតុអ្វីក៏លោកឱ្យឈ្មោះថាសប្បុរសធម៌ ?

វិ. បានជាលោកឱ្យឈ្មោះថា សប្បុរសធម៌ គឺជាធម៌របស់សប្បុរសទាំងឡាយ លោកតែងតែរាប់អានគោរពបូជារស់កាលជានិច្ចជាប្រក្រតីពុំដែលដាច់ ។

បុ. ហេតុអ្វីក៏លោកឱ្យឈ្មោះថាមនុស្សធម៌ ?

វិ. បានជាលោកឱ្យឈ្មោះថាមនុស្សធម៌ គឺជាធម៌មានផលនឹងជួយទ្រទ្រង់ជាតិរបស់មនុស្សមិនឱ្យធ្លាក់ទៅកាន់ទីទាប នឹងឱ្យបានសម្រេចជាតិកំណើតជាទេវតាដោយពិត ។

បុ. ឯកិច្ចដែលនឹងទទួលសមាទាននូវព្រះត្រៃសរណគមន៍ នឹងបញ្ចសីលនេះ តើអ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើមលោកមិនបានកំណត់ថ្ងៃខែទេ ឬ ក៏សុទ្ធតែមានកំណត់ដែរ ?

វិ. លោកមិនបានកំណត់ថ្ងៃ ខែទេ នឹងសមាទានថ្ងៃណាខែណាក៏ចេះតែបានឥតមានទាស់ខុសអ្វីឡើយ ទទួលតែម្តងបើមិនមានសៅហ្មងទេ រក្សាឥរាបដល់អស់មួយជីវិតទៅក៏បាន, បើមានសៅហ្មង ឬមានរង្កៀសសង្ស័យត្រង់សិក្ខាបទណាមួយហើយ ត្រូវឱ្យទទួលសមា

ទានជាថ្មីម្តងទៀតទើបគួរ ។

ឬ. ចុះចំណែកខាងអដ្ឋង្គិកសីល គឺសីលដែលប្រកបដោយទាំង ៨ នេះ សប្បុរសទាំងឡាយណាមួយបានសមាទានឱ្យកើតឡើងក្នុងសន្តានប្រាកដហើយនោះ តើនឹងញ៉ាំងគុណវិសេសឱ្យកើតឡើងដូចម្តេចខ្លះ ?

វ. អាចញ៉ាំងសេចក្តីជ្រះថ្លាខ្លាំងឱ្យកើតឡើង ប្រាកដក្នុងចិត្ត ហើយមានប្រាថ្នាដើម្បីនឹងធ្វើនូវការទានកិច្ច គឺថាជាកិច្ចដែលត្រូវចំរើនឱ្យច្រើនឡើងទៅ១ , មួយទៀតដើម្បីនឹងធ្វើនូវតណ្ហាទាំង៦មានរូបតណ្ហាជាដើមឱ្យទ្រុឌទ្រោមថយកម្លាំងទៅ១ , ដើម្បីនឹងតាំងនៅនៃការទានដែលជាឧបនិស្ស័យធម៌ឱ្យមានកម្លាំងខ្លាំងឡើងទៅ១, ដើម្បីនឹងញ៉ាំងមគ្គផលឱ្យកើតឡើងក្នុងលោកនេះនិងលោកខាងមុខ១ ។

ហេតុនេះហើយបានជាសប្បុរសទាំងឡាយ លោកតែងលះបង់នូវការងារទាំងពួង មានការក្សួររាស់ជាដើមហើយគប្បីចូលទៅសមាទានរក្សានូវអដ្ឋសីល (ដែលលោកហៅថា ឧបោសថសីល) ក្នុងទីវត្តអារាមព្រះវិហារ ដើម្បីនឹងជម្រះសន្តានចិត្តរបស់ខ្លួនឱ្យស្អាតបរិសុទ្ធ

ម៉ត់ចត់ អស់ថ្ងៃ១ យប់១ តាមពុទ្ធានុញ្ញាតដោយពិត ។

បុ. កាលបើសប្បុរសទាំងឡាយមានសទ្ធាជ្រះថ្លាជឿជាក់ក្នុងព្រះពុទ្ធសាសនាហើយ បានទទួលព្រះត្រៃសរណគមន៍និងសមាទានទូវសីលបើចង់ឱ្យមាននាមព្រាកដថាជាឱ្យបាសកឧបាសិកា មុនដំបូងត្រូវឱ្យធ្វើដូចម្តេច ?

វិ. មុនដំបូងសមាទានសីល គប្បីថ្វាយខ្លួនចំពោះព្រះរតនត្រ័យជាមុនសិន ហើយសឹមសមាទានសីលជាខាងក្រោយ ធ្វើយ៉ាងនេះទើបបានឡើងពេញទីជាឧបាសកឧបាសិកា ។

បុ. បាលីសូមខមាទោសនឹងបាលីសូត្រប្រកាសខ្លួនទាំងពីរបទនេះ តើត្រូវឱ្យសូត្ររាល់ថ្ងៃឧបោសថ ឬ ដូចម្តេច ?

វិ. បាលីទាំងពីរបទនេះ មិនចាំបាច់សូត្ររាល់ថ្ងៃឧបោសថទេ ត្រូវសូត្រតែត្រង់ថ្ងៃដែលខ្លួនចូលមកសមាទានជាដំបូងតែម្តង ក៏បានហើយ ។

បុ. សប្បុរសទាំងឡាយដែលបានរក្សាទូវឧបោសថសីលរួចហើយកាលបើជិតដល់ថ្ងៃរក្សាឧបោសថសីលម្តងទៀត តើត្រូវធ្វើដូចម្តេច ?

វ. កាលបើជិតដល់ថ្ងៃឧបោសថម្តងទៀត គប្បីចាត់ចែងនូវការងារទាំងឡាយមានអាហារភោជនជាដើម ដែលខ្លួនគប្បីធ្វើក្នុងថ្ងៃឧបោសថ នោះឱ្យហើយស្រេចពីថ្ងៃមុន លុះដល់ថ្ងៃដែលខ្លួនត្រូវរក្សានូវឧបោសថនោះហើយគប្បីភ្ញាក់ពីព្រលឹម ហើយខ្ពុរមាត់ជម្រះធ្មេញឱ្យស្អាតតាំងចិត្តវៀរចាកហេតុជាទីទំលាយនូវសីលនោះ ឱ្យគ្រប់សិក្ខាបទទាំងអស់ទើបគួរ ។

ប. បើទៅសមាទានពីព្រលឹមមិនរួច ដោយមានកិច្ចរវល់ជាច្រើនលុះដល់ពេលថ្ងៃទើបទៅសមាទាន តើឧបោសថរបស់បុគ្គលនោះនឹងបានឡើងពេញទីអស់ថ្ងៃ១យប់១ដែរឬ ? ត្រូវឱ្យធ្វើដូម្តេច ?

វ. បើឃើញថា ទៅសមាទានពីព្រលឹមមិនរួចទេ ដោយមានកិច្ចរវល់ជាច្រើននោះ គប្បីអធិដ្ឋាននូវឧបោសថកំណត់តាំងចិត្តថានឹងរក្សាអស់ថ្ងៃ១យប់១ ដូច្នេះសម្បូរសទាំងឡាយ គប្បីរៀបចំនូវប្រដាប់ប្រដាមានទៀននឹងធូបជាដើម ហើយចូលទៅកាន់វត្តអារាមឬទីលានព្រះចេតិយ ឬ ទីណាដែលមានភិក្ខុ-សាមណេរ ឬបុគ្គលណាមួយដែលគេបានសមាទានអំពីមុនខ្លួនរួចមកហើយ ក៏ត្រូវទៅសូមសមាទានអំពី

គេក៏បានឥតមានទាស់ខុសអ្វីឡើយ ។

បុ. ក្នុងខណៈដែលសប្បុរសទាំងឡាយ បានទទួលនូវសីល ហើយតើត្រូវតាំងចិត្តវៀរដូចម្តេចខ្លះ ?

វិ ត្រូវឱ្យតាំងចិត្តវៀរចាកទោសនោះៗ តាមបង្គាប់ដែលមានមកក្នុងសិក្ខាបទនីមួយៗ ត្រូវតាំងចិត្តវៀរឱ្យគ្រប់សិក្ខាបទទាំង៨ ទើបបានឈ្មោះថាជាអ្នករក្សាសីលដោយពិតប្រាកដមែន ។

បុ. បើរក្សាសីលតែម្យ៉ាង តើនឹងបានព្រះនិព្វានដែរឬទេ ?

វិ. បើរក្សាសីលមិនបានព្រះនិព្វានទេ ហេតុអ្វីក៏អានិសង្សសីលថា សីលេន និព្វុតឹយន្តិ សត្វទាំងឡាយដែលទៅកាន់ព្រះនិព្វានក៏ដោយសីល ពាក្យនេះមិនខុសទៅហើយឬ ?

វិ. មិនខុសទេ ពិតមែនតែដូច្នោះ សីលនេះជាប្រធានឱ្យបានព្រះនិព្វាន រក្សាតែមួយៗមិនបានទេ លុះត្រាតែរក្សា សីល សមាធិ បញ្ញា ទាំងបីនេះទើបសំរេចព្រះនិព្វានបាន សីលនេះជាប្រធានលោកឧបមាដូចជាផែនដីជាប្រធាននៃរុក្ខជាតិនិងតិណជាតិយ៉ាងណាចំណែកសីលជាទីបណ្តុះនៃកុសលទាំងអស់ ក៏យ៉ាងនោះដែរ ។

បុ. និច្ចសីលនិងឧបោសថសីល និច្ចសីលរក្សាដើម្បីអ្វី ? ឧបោសថសីលរក្សាដើម្បីអ្វី ?

វិ. និច្ចសីលរក្សាដើម្បីបិទបាំងផ្លូវអបាយ, ឧបោសថសីលរក្សាដើម្បីបើកផ្លូវទៅកាន់ព្រះនិព្វាន ។

បុ. អ្វីជាតួសីល ? ព្រោះហេតុអ្វី ?

វិ. ចេតនាជាតួសីល ព្រោះព្រះពុទ្ធដីកាទ្រង់ត្រាស់សំដែងថា "ចេតនាហំ ភិក្ខវេ សីលំ វទាមិ" ម្នាលភិក្ខុទាំងឡាយតថាគតពោលថាចេតនាជាតួសីល ។

បុ. ចេតនាដែលនឹងនាំឱ្យកើតសីលនោះមានប៉ុន្មាន ?

វិ. ចេតនាដែលនាំឱ្យកើតសីលនោះមាន៣យ៉ាងគឺ:

**១-សម្បត្តវិរតិ** ចេតនាវៀរដោយវត្ថុដល់ព្រម គួរប្រព្រឹត្តកន្លងសិក្ខាបទ មិនហ៊ានប្រព្រឹត្តកន្លងខ្លាចដាច់សីល,

**២-សមាទានវិរតិ** ចេតនាវៀរដោយសមាទាន,

**៣-សមុច្ឆេទវិរតិ** ចេតនាជាហេតុលះកិលេសដាច់ស្រឡះដោយអរិយមគ្គ ។

ចប់ពាក្យបុច្ឆា-វិសជ្ជនា ឧបោសថវិន័យ្ស័យដោយសង្ខេប ។

ទីបំផុតនេះ ខ្ញុំបម្រុងនឹងរៀបរៀងប្រស្នាធម្មវិន័យនេះឱ្យបាន ពិស្តារព្រោះថានៅមានប្រស្នាជាសារៈសំខាន់ៗ ជាច្រើន ប៉ុន្តែពុំមាន ឱកាសសោះ ពេលក្រោយបើមានឱកាស ខ្ញុំនឹងបំពេញឱ្យបានរឹងរឹតតែ ពិស្តាតទៅទៀត ។

## មានលក់ដុំ និង លក់រាយ

នូវសៀវភៅគ្រប់មុខគ្រប់ប្រភេទ នៅ

"បណ្ណាគារត្រៃរតន៍" ផ្ទះលេខ 136Eo

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។



បោះពុម្ពនៅរោងពុម្ពឈាសិរី ២ ធ្នូ

ទូរស័ព្ទលេខ: ០១៨.៨១០.១៦៧_០២៣.៧២.៤៥.០៧